ក្រុមសៀវភៅការរុករកឃើញ®

ប្រាជ្ញាក្នុងព្រះគម្ពីរសម្រាប់ឪពុកម្តាយ

# ជំនួយសម្រាប់ ឪពុកម្តាយ ដែលកូនមាន បញ្ហាក្នុងការសិក្សា



និពន្ធដោយ : Ruth Wan-Lau



*សេចក្តីផ្តើម*

# ការប្រណាំងប្រជែងក្នុងការសិក្សា

**អេម៉ា(Emma) មានអាយុតែ៣ឆ្នាំទេ** ហើយនៅ២ឆ្នាំទៀត ទើបគ្រប់អាយុចូលរៀន ប៉ុន្តែ នាងបានចូលរៀនថ្នាក់ភាសាអង់គ្លេស រៀងរាល់សប្តាហ៍រួចទៅហើយ។ អ្នកស្រីមីស៊ែល(Michelle) បានពន្យល់ថា មូលហេតុដែលគាត់ឲ្យកូនឆាប់ចូលរៀនដូចនេះ គឺដោយសារក្មេងៗដទៃ ដែលមានអាយុដូចនាង ក៏កំពុងតែរៀននៅថ្នាក់ភាសាអង់គ្លេសដែរ។ គាត់ថា នាងចាំបាច់ត្រូវរៀនអានសៀវភៅ ក្នុងពេលឆាប់ៗនេះ ដើម្បីឲ្យនាងរៀនឲ្យទាន់គេ។

អ៊ីសាក់(Isaac)ជាក្មេងដែលមានអាយុ៩ឆ្នាំ។ គាត់បានទៅរៀនភាសាចិនក្នុងវគ្គសិក្សាបីខុសគ្នា ដែលសុទ្ធតែត្រូវបង់ថ្លៃសិក្សា។ រៀងរាល់សប្តាហ៍ គាត់ទៅរៀននៅសាលាឈ្នួល និងមានគ្រូមកបង្រៀនសរសេរតែងសេចក្តី នៅផ្ទះ និងបានរៀនបំប៉នជំនាញនិយាយភាសាចិន ដោយមាននិស្សិតមហាវិទ្យាល័យម្នាក់បង្រៀនគាត់ តាមអនឡាញ ពីប្រទេសចិន។

ខ្លូឌា(Claudia) កំពុងតែរៀនគួរបំប៉ន ដើម្បីត្រៀមខ្លួនប្រឡងបញ្ចប់សាលាបឋម មុននឹងចូលរៀនថ្នាក់អនុវិទ្យាល័យ នៅឆ្នាំបន្ទាប់។ អ្នកស្រីអ៊ែនជែលីន(Angeline) ដែលជាម្តាយរបស់ក្មេងស្រីអាយុ១១ឆ្នាំនេះ ក៏បានលប់ចោលគម្រោងដំណើរកម្សាន្តវិស្សមកាល ជាលក្ខណៈគ្រួសារ ដើម្បីឲ្យខ្លូឌាបានរៀនគួរបំ

ប៉ន។ គាត់ថា "ខ្ញុំចង់ឲ្យកូនស្រីខ្ញុំចូលរៀននៅសាលាដែលល្អបំផុត ដូចនេះ ខ្ញុំក៏បានឲ្យនាងទៅរៀនគួរបន្ថែម"។

នៅតាមបណ្តាប្រទេសជាច្រើន កុមារបានទទួលរងសម្ពាធដ៏ធ្ងន់ធ្ងរ ឲ្យខិតខំរៀនឲ្យពូកែ។ ឧទាហរណ៍ នៅប្រទេសសឹង្ហបូរី វាជារឿងធម្មតាទៅហើយ ដែលក្មេងមិនទាន់គ្រប់អាយុចូលរៀន បានទៅរៀនថ្នាក់បំប៉ន ហើយក្មេងៗដែលមានអាយុកាន់តែច្រើន ក៏បានទៅរៀនកាន់តែច្រើនជាងក្មេងនៅប្រទេសដទៃ។

ឪពុកម្តាយមួយចំនួន មិនខុសពីអ្នកស្រីមីសែលទេ គឺបានបញ្ជូនកូនរបស់ខ្លួនឲ្យទៅរៀននៅសាលា ពេលដែលពួកគេមានអាយុ៣ឆ្នាំ។ អ្នកផ្សេងទៀតបានធ្វើដូចឪពុកម្តាយរបស់អ៊ីសាក់ដែរ ដោយបង់ប្រាក់ឲ្យកូនរបស់ខ្លួន ទៅរៀន នៅថ្នាក់រៀនបីផ្សេងគ្នា សម្រាប់មួយមុខវិជ្ជា។

ជាលទ្ធផល ក្មេងៗជាច្រើនមានពេលតិចតួច សម្រាប់លេង ឬសម្រាក។ ពួកគេក្រចូលគេង មានកិច្ចការសាលាច្រើនពេក និងកិច្ចការបន្ថែមទៀត ដែលឪពុកម្តាយពួកគេបានដាក់ឲ្យធ្វើ។ ប៉ុន្តែ ឪពុកម្តាយជាច្រើនបាននិយាយថា ពួកគេកំពុងតែឲ្យកូនរៀនច្រើនយ៉ាងនេះ គឺដោយសារកូនរបស់ពួកគេ កំពុងតែចម្រើនវ័យធំឡើង ក្នុងបរិយាកាសប្រកួតប្រជែងខ្លាំង។

យ៉ូអែល(Joel) ដែលជាក្មេងអាយុ១២ឆ្នាំបាននិយាយថា "ក្នុងថ្នាក់រៀនរបស់ខ្ញុំ ម្នាក់ៗសុទ្ធតែមានស្ត្រេស។ គ្រូរបស់យើងបានប្រាប់យើងថា ពន្ទុះប្រឡងរបស់យើង នឹងមានផលប៉ះពាល់មកលើការងារ ដែលយើងនឹងស្វែងរក និងប្រាក់ចំណូល ព្រមទាំងមានផលប៉ះពាល់មកលើការរស់នៅរបស់យើង នៅពេលអនាគតផងដែរ។ ម្នាក់ៗមានអារម្មណ៍ថា ដូចជាចង់បោះបង់ការសិក្សាបន្ទាប់ពីបានឮគ្រូប្រាប់ដូចនេះ?"

ក្នុងនាមយើងជាឪពុកម្តាយ យើងចង់ឲ្យកូនយើងទទួលបានអ្វីដែលល្អបំផុត។ យើងចង់ឲ្យពួកគេមានអនាគតត្រចះត្រចង់ និងជោគជ័យក្នុងជីវិត។ យើងមិនអាចធ្វើអ្វីច្រើន ដើម្បីផ្លាស់ប្តូរប្រព័ន្ធនៃសង្គម ដែលយើងកំពុងតែរស់នៅ ដូចនេះ យើងក៏បានប្រើធនធានទាំងអស់ ដែលយើងមាន ដើម្បីធ្វើយ៉ាងណា ឲ្យកូនៗ

របស់យើងទទួលបាននូវឱកាសល្អបំផុត។ តើយើងធ្វើរឿងទាំងអស់នេះ ដោយសារយើងស្រឡាញ់កូនរបស់យើងមែនទេ?

វាជារឿងធម្មតាទេ ដែលយើងចង់ឲ្យកូនយើងទទួលបានអ្វីៗដែលល្អបំផុត តែទោះជាយ៉ាងណាក៏ដោយ បើយើងមិនប្រយ័ត្នទេ យើងអាចធ្លាក់ចូលទៅក្នុងអន្ទាក់នៃការប្រឹងប្រែង និងចង់បានជ្រុល។ ក្នុងនាមយើងជាគ្រីស្ទបរិស័ទ យើងចាំបាច់ត្រូវផ្គាប់ចិត្តព្រះ ក្នុងគ្រប់ការទាំងអស់ ដោយរាប់បញ្ចូលទាំងការនាំផ្លូវកូនយើង ឆ្លងកាត់ការប្រណាំងប្រជែង ក្នុងការរៀនសូត្រ។ ដើម្បីជៀសវាងការដើរផ្លូវខុស យើងចាំបាច់ត្រូវដាក់យុថ្កានៃជីវិតយើង ឲ្យជាប់នឹងព្រះបន្ទូលព្រះ ពោលគឺនៅជាប់នឹងព្រះ។ ដូចនេះ ចូរយើងចំណាយពេលជញ្ជឹងគិត ដោយសួរខ្លួនឯងថា តើព្រះសព្វព្រះទ័យឲ្យយើងយកចិត្តទុកដាក់ចំពោះការអប់រំរបស់កូនយើងខ្លាំងប៉ុណ្ណា បើធៀបនឹងអាទិភាពផ្សេងទៀត? តើព្រះអង្គមានបន្ទូលថា យើងត្រូវយកអ្វីជាអាទិភាព សម្រាប់កូនយើង? តើព្រះអង្គមានបន្ទូលថា កូនរបស់យើងគួរតែរៀនអ្វីខ្លះ? តើធ្វើដូចម្តេចឲ្យយើងអាចគ្រប់គ្រងការភ័យខ្លាច ដែលយើងមាន?

សូមយើងស្វែងយល់អំពីបញ្ហាទាំងនេះទាំងអស់គ្នា។

Ruth Wan-Lau

# មាតិកា

*ទី១*

កូនជាអំណោយមកពីព្រះ……………………………………………………៧

*ទី២*

ឪពុកម្ដាយ គឺជាអ្នកបម្រើរបស់ព្រះ........................................១១

*ទី៣*

ការរៀនសូត្រ គឺជាការរៀនអំពីព្រះ និងស្នាព្រះហស្តព្រះអង្គ........១៧

*ទី៤*

ការសម្រាក ក្នុងច្បាប់របស់ព្រះ.............................................២៣

*ទី៥*

រស់នៅដោយប្រាជ្ញាមកពីព្រះ................................................២៩

EDITORS: Chia Poh Fang, Amos Khan, Leslie Koh

COVER DESIGN: Mary Tham

COVER IMAGE: Shutterstock

INTERIOR DESIGN: Mary Tham

INTERIOR IMAGES: Shutterstock

បទគម្ពីរជាភាសាខ្មែរដកស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធ ភាសាខ្មែរ បកប្រែចាស់ ឆ្នាំ ១៩៥៤ ដោយការអនុញ្ញាតិ និងរក្សាសិទ្ធិដោយសមាគមន៍ព្រះគម្ពីរសកល (បានដកស្រង់ ដោយរក្សាអក្ខរាវិរុទ្ធដើម)។

All rights reserved

© 2021 Our Daily Bread Ministries



*ទី១*

## កូនជាអំណោយមកពីព្រះ

**ពេលអ្នកមើលទៅកូនរបស់អ្នក តើអ្នកឃើញអ្វី?**

"ខ្ញុំឃើញមនុស្សម្នាក់ដែលត្រូវចិញ្ចឹម។"

"ខ្ញុំមើលឃើញខ្លួនខ្ញុំ"។

"ខ្ញុំមើលឃើញមនុស្សម្នាក់ ដែលនឹងមានជីវិតប្រសើរជាងខ្ញុំ"។

ក្មេងៗមានសារៈសំខាន់ជាច្រើន ចំពោះឪពុកម្តាយរបស់ពួកគេ។ ប៉ុន្តែ ព្រះគម្ពីរប៊ីបបានជួយឲ្យយើងដឹងថា កូនយើងជានរណាពិតប្រាកដៈ ពួកគេជាអំណោយមកពីព្រះអម្ចាស់(ទំនុកដំកើង ១២៧:៣)។

> *ដ្បិតគឺទ្រង់ដែលបានបង្កើតចិត្តថ្លើមនៃទូលបង្គំ ហើយបានផ្សំគ្រឿងនៃទូលបង្គំនៅក្នុងផ្ទៃម្តាយ ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់ ដ្បិតទ្រង់បានបង្កើតទូលបង្គំមកយ៉ាងគួរកោត គួរអស្ចារ្យ ឯស្នាដៃនៃទ្រង់ ក៏សុទ្ធតែអស្ចារ្យទាំងអស់ ព្រលឹងទូលបង្គំក៏ដឹងច្បាស់ហើយ(ទំនុកដំកើង ១៣៩:១៣-១៤)។*

កូនៗរបស់យើង មានប្រភពមកពីព្រះជាម្ចាស់។ ព្រះអង្គបានបង្កើតពួកគេ

ម្នាក់ៗមក ដោយសេចក្ដីស្រឡាញ់ ហើយបានប្រទានពួកគេមកយើង ជាអំណោយដ៏មានតម្លៃ ដែលយើងត្រូវថែរក្សាទុក។ ក្មេងម្នាក់ៗត្រូវបានព្រះអង្គបង្កើតមក ឲ្យមានលក្ខណៈពិសេសខុសៗគ្នា។ សូមយើងចំណាយពេលបន្តិចដើម្បីស្ញើចសរសើរ ចំពោះសេចក្ដីពិតដ៏ស៊ីជម្រៅ ក្នុងព្រះគម្ពីរ ដែលចែងថា : ក្មេងម្នាក់ៗពិសេសរៀងៗខ្លួន និងមានវិញ្ញាណដ៏អស់កល្ប។ ក្នុងពិភពលោករបស់ព្រះជាម្ចាស់ គឺគ្មានមនុស្សណាមានលក្ខណៈដូចគ្នាទាំងស្រុងឡើង គឺសូម្បីតែក្នុងចំណោមកូនភ្លោះក៏ដោយ។ ក្នុងពេលវេលាដ៏វែង ក្នុងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល គឺនឹងគ្មាននរណាម្នាក់ ដូចកូនអ្នកឡើយ ក្នុងចក្រវាលទាំងមូល។

ដូចនេះ តើយើងអាចយកសេចក្ដីពិតក្នុងព្រះគម្ពីរនេះ មកអនុវត្តក្នុងការប្រកួតប្រជែងក្នុងការរៀនសូត្ររបស់កូនយើង យ៉ាងដូចម្ដេច?

## ចូរជៀសវាងការប្រៀបធៀប

យើងត្រូវដឹងថា ក្មេងម្នាក់ៗមានលក្ខណៈពិសេស។ ការដឹងយ៉ាងដូចនេះ ជួយឲ្យយើងជៀសវាងការប្រៀបធៀប ដែលជាអន្ទាក់ដែលគ្រោះថ្នាក់បំផុត ក្នុងការចិញ្ចឹមកូន។ ទោះកូនៗរបស់យើងប្រហែលជាមានមុខមាត់ និងមានចរិយាសម្បត្តិ កាត់រកយើងក៏ដោយ ក៏ពួកគេមិនមែនជាយើងនោះទេ ។ ការប្រៀបធៀបពួកគេ ជាមួយនឹងខ្លួនយើង គឺមិនមានប្រយោជន៍អ្វីទេ។

ស្រដៀងគ្នានេះដែរ យើងគួរតែជៀសវាងការប្រៀបធៀបកូនយើង ជាមួយក្មេងដទៃ ទោះពួកគេជាបងប្អូនបង្កើត ឬមិត្តភក្ដិរបស់ពួកគេក្ដី។

## ការប្រៀបធៀបអាចនាំឲ្យមានការមិនសប្បាយចិត្តជាច្រើន។

អ្នកស្រីអេសធើរ(Esther) មានអារម្មណ៍កាន់តែថប់បារម្ភ ពេលដែលនាងបានស្ដាប់មិត្តរួមការងាររបស់នាង ឈ្មោះចេស៊ីកា(Jessica) បានអួតថា "កូនស្រីខ្ញុំ(ឈ្មោះម៉ី លីង Mei Ling) បានទៅរៀនមុខវិទ្យាវិទ្យាសាស្ត្រ នៅថ្នាក់បំប៉នដ៏ល្បីល្បាញ។ នាងបានរៀនវិធីសាស្ត្រប្រឡង ហើយក៏រៀនបានពិន្ទុខ្ពស់ជាងគេ នៅក្នុងថ្នាក់!" ពេលនោះ អ្នកស្រីអេសធើរក៏បានសួរខ្លួនឯងថា

តើនាងគួរតែបញ្ជូនកូនប្រុសគាត់(ឈ្មោះដានីយ៉ែល) ឲ្យទៅរៀនកម្មវិធីនោះដែរឬយ៉ាងណាទេ? ពេលគាត់ទៅដល់ផ្ទះ គាត់ក៏បានប្រាប់ដានីយ៉ែលថា "ម៉ីលីងជាសិស្សដែលទទួលបានពិន្ទុច្រើនជាងគេ ក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ! កូនគួរតែខំរៀនឲ្យពូកែដូចនាង!"

ព្រះគម្ពីរបានរំឭកយើងថា ក្មេងម្នាក់ៗមានលក្ខណៈពិសេសរៀងៗខ្លួន។ ក្មេងម្នាក់ៗមានចំណុចខ្លាំង និងចំណុចខ្សោយផ្សេងៗពីគ្នា។ គ្មានក្មេងណាដែលសុទ្ធតែពូកែគ្រប់មុខវិជ្ជា គ្រប់ជំនាញ និងគ្រប់កិច្ចការនោះទេ។ ពេលណាយើងប្រៀបធៀបកូនយើង ជាមួយកូនអ្នកដទៃ គឺមានន័យថា យើងកំពុងតែព្យាយាមរុញច្រានពួកគេឲ្យចូលទៅក្នុងពុម្ពជីវិតរបស់អ្នកដទៃ ដែលព្រះបានកំណត់ទុកជាមុនសម្រាប់តែពួកគេ។

ការជៀសវាងការប្រៀបធៀប នឹងជួយឲ្យយើងមានការរំពឹងចង់បាន ដែលសមហេតុផល ពីការធ្វើដំណើររបស់ក្មេងម្នាក់ៗ ក្នុងការរៀនសូត្រ។ យើងនឹងអាចជៀសវាងការថប់បារម្ភដែលមិនចាំបាច់ បើសិនជាយើងចងចាំថា យើងមិនអាចរំពឹងថា ក្មេងម្នាក់ៗនឹងរៀនពូកែដូចគ្នា ក្នុងមុខវិជ្ជានីមួយៗនោះឡើយ។

## កូនរបស់អ្នកជាអំណោយ មិនមែនជាផលិតផលនោះទេ

មនុស្សភាគច្រើននឹងបដិសេធភ្លាម បើសិនជានរណាម្នាក់និយាយថា ក្មេងៗមានលក្ខណៈដូចផលិតផលប្រើប្រាស់។ ប៉ុន្តែ តើយើងអាចភ្លាត់ជើងធ្លាក់ចូល ទៅក្នុងការចាត់ទុកពួកគេ ជាផលិតផលដែរឬទេ?

តាមធម្មតា យើងចង់បានការពេញចិត្ត ចំពោះផលិតផលអ្វីមួយ ដែលយើងបានទិញ។ បើយើងមិនសប្បាយចិត្តចំពោះពួកវា យើងឈប់ប្រើពួកវា ឬព្យាយាមកែលម្អវាឲ្យល្អជាងមុន។ ហើយពេលណាយើងមិនសប្បាយចិត្តនឹងផលិតផលដែលយើងបានទិញ យើងចូលចិត្តនិយាយអួតអំពីវា ព្រោះផលិតផលដែលល្អ ក៏ធ្វើឲ្យគេសរសើរម្ចាស់របស់វាផងដែរ តើមែនទេ?

តើយើងអាចចាត់ទុកកូនរបស់យើង យ៉ាងដូចនេះដែរឬ?

ពេលណាកូនយើងមិនបានទទួលលទ្ធផលល្អ យើងមិនសប្បាយចិត្តចំពោះ

ពួកគេមែនទេ? តើយើងនិយាយ ឬធ្វើអ្វីដែលធ្វើឲ្យពួកគេមានអារម្មណ៍ថា យើងបានបដិសេធពួកគេឬទេ? តើយើងព្យាយាម "កែលម្អ" ពួកគេ ដោយឲ្យពួកគេទៅរៀនគួរបន្ថែមឬ? ពេលពួកគេរៀនពូកែ តើយើងនិយាយអួតប្រាប់គេ អំពីជោគជ័យរបស់ពួកគេឬ? តើយើងចង់ឲ្យកូនយើងរៀនពូកែ ដើម្បីឲ្យគេសរសើរយើងផងដែរឬ?

ព្រះគម្ពីរបានប្រាប់យើងថា កូនយើងមិនមែនជាផលិតផលនោះទេ តែជាមនុស្ស ។ ពួកគេជាមនុស្សដែលមានលក្ខណៈពិសេសរៀងៗខ្លួន ដែលព្រះជាម្ចាស់បានប្រទានមកយើង។ យើងមិនត្រូវមានផ្នត់គំនិត ដែលទាមទាភាពជោគជ័យ យ៉ាងដូចនេះថា "ម៉ាក់(ឬប៉ា) នឹងសប្បាយចិត្តបើសិនជាកូន(ផលិតផលរបស់ប៉ា ឬម៉ាក់) ឈានដល់ស្តង់ដាមួយ ដែលម៉ា(ឬប៉ា)ពេញចិត្ត"។ តែផ្ទុយទៅវិញ ចូរយើងប្រកាន់យកផ្នត់គំនិត ជាអ្នកបម្រើដែលស្មោះត្រង់វិញ ។ ភារៈកិច្ចជាឪពុកម្តាយគឺជាឯកសិទ្ធិ ដែលបានធ្វើជាអ្នកបម្រើដ៏ស្មោះត្រង់របស់ព្រះ ព្រោះកូនម្នាក់ៗ គឺជាអំណោយដ៏ពិសេស មកពីព្រះអម្ចាស់។ នៅក្នុងជំពូកបន្ទាប់ យើងនឹងនិយាយ អំពីអាទិភាពទីមួយ នៃភារៈកិច្ចជាឪពុកម្តាយ។

## ការពិចារណា

១. តើធ្វើដូចម្តេច ឲ្យខ្ញុំអាចរំឭកខ្លួនឯង ជារៀងរាល់ថ្ងៃថា កូនរបស់ខ្ញុំជាវិញ្ញាណដែលពិសេស និងអស់កល្បជានិច្ច ដែលព្រះជាម្ចាស់បានបង្កើតមក?

២. តើធ្វើដូចម្តេច ឲ្យខ្ញុំអាចជៀសវាងការប្រៀបធៀបកូនរបស់ខ្ញុំ នឹងបងប្អូន ឬមិត្តភក្តិរបស់ពួកគេ?

៣. តើខ្ញុំប្រហែលជាកំពុងតែចាត់ទុកកូនរបស់ខ្ញុំ ជាផលិតផល ដោយរបៀបណាខ្លះ?



*ទី២*

# ឪពុកម្តាយ គឺជាអ្នកបម្រើរបស់ព្រះ

**អ្នកស្រីឃែរ៉ូល(Carol) បានស្រែកឮៗថា** “បេនយ៉ាមីន ពាក់ស្បែកជើង!” កូនរបស់គាត់ ដែលមានអាយុ៤ឆ្នាំ កំពុងតែហួសម៉ោងទៅរៀនបំប៉នមុខវិជ្ជាគណិតវិទ្យាហើយ។ អ្នកស្រីឃែរ៉ូលក៏បានយកគាត់ទៅដាក់នៅថ្នាក់រៀន ហើយបន្ទាប់មក ក៏បានទៅទទួលគាត់ ពេលចប់ម៉ោងរៀន។ នៅតាមផ្លូវទៅផ្ទះ អ្នកស្រីឃែរ៉ូលក៏បានសួរគាត់ថា “តើកូនមានកិច្ចការដែលគ្រូដាក់ឲ្យធ្វើនៅផ្ទះទេ?” បេនយ៉ាមីនក៏បានងក់ក្បាល។ មុនពេលអាហារពេលល្ងាច គាត់ត្រូវមើលវីដេអូមួយដែលមានរយៈពេលមួយម៉ោង។ វីដេអូនោះមានការបង្ហាញអក្សរចិន នៅលើសន្លឹកកាតដែលមានរូប។ អ្នកស្រីឃែរ៉ូលក៏បានគិតក្នុងចិត្តថា “ខ្ញុំនឹងធ្វើតេស្តបេនយ៉ាមីន ដោយប្រើសន្លឹកកាតដែលមានរូប បន្ទាប់ពីគាត់បញ្ចប់លំហាត់គណិតវិទ្យាដែលគ្រូបានដាក់ឲ្យគាត់ធ្វើនៅផ្ទះ។ ខ្ញុំពិតជា ចង់ឲ្យគាត់រៀនឲ្យចេះលឿនជាងគេ!”

ក្នុងនាមជាឪពុកម្តាយ ជារៀងរាល់ថ្ងៃ យើងច្រើនតែគិត អំពីតម្រូវការរបស់កូនៗ។ ទោះយើងមិនបាននៅជាមួយពួកគេ តែចិត្តរបស់យើងបានបន្តគិតអំពីតម្រូវការ និងការទទួលខុសត្រូវ ចំពោះសុខុមាលភាពរបស់ពួកគេ។ តើកូនខ្ញុំបានគេងថ្ងៃទេ ថ្ងៃនេះ? ហេតុអ្វីនាងចេះតែមានជំងឺ? តើខ្ញុំត្រូវធ្វើដូចម្តេច ដើម្បីឲ្យគាត់ឈប់រឹងចចេស? តើធ្វើដូចម្តេចឲ្យគាត់ឈប់យំឡាំប៉ា? ហេតុអ្វីគាត់នៅតែមិនអាច

អង្គុយឲ្យស្ងៀម នៅក្នុងថ្នាក់រៀន? តើខ្ញុំគួរតែបញ្ជូនគាត់ ឲ្យទៅរៀនបន្ថែមឬទេ? ហេតុអ្វីបានគាត់មិនសូវយកចិត្តទុកដាក់ នៅក្នុងការប្រឡង? តើខ្ញុំគួរតែលើកទឹកចិត្តគាត់យ៉ាងដូចម្តេច ដើម្បីឲ្យគាត់ខិតខំរៀនជាងមុខ?

*យើងមានការព្រួយបារម្ភ ព្រោះយើងស្រឡាញ់កូនៗរបស់យើង ហើយចង់ឲ្យពួកគេទទួលបានអ្វីដែលល្អបំផុត។ ប៉ុន្តែ ការព្រួយបារម្ភអំពីកូន មិនមែនជាកិច្ចការសំខាន់បំផុត ដែលយើងត្រូវធ្វើ ក្នុងនាមជាឪពុកម្តាយឡើយ។ ព្រះគម្ពីរប៊ីបបានរំឭកយើងយ៉ាងច្បាស់ អំពីកិច្ចការសំខាន់បំផុត ដែលយើងត្រូវយកជាអាទិភាព។ គឺដូចមានសេចក្តីថែងថា ចូរបង្ហាត់កូនក្មេង ឲ្យប្រព្រឹត្តតាមផ្លូវដែលគួរប្រព្រឹត្តនោះវានឹងមិនលះបង់ពីផ្លូវនោះដរាបដល់ចាស់(សុភាសិត ២២:៦)។*

*ត្រូវឲ្យឯងស្រឡាញ់ព្រះយេហូវ៉ា ជាព្រះនៃឯងឲ្យអស់ពីចិត្ត អស់ពីព្រលឹង ហើយអស់ពីកំឡាំងឯង សេចក្តីទាំងនេះដែលអញបង្គាប់ដល់ឯងនៅថ្ងៃនេះ នោះត្រូវនៅជាប់ក្នុងចិត្តឯងចុះ ត្រូវឲ្យប្រិតប្រៀនសេចក្តីទាំងនេះដល់កូនចៅឯង ព្រមទាំងនិយាយដំណាល ក្នុងកាលដែលអង្គុយនៅក្នុងផ្ទះហើយដើរតាមផ្លូវ ក្នុងកាលដែលដេក ហើយក្រោកឡើងផង ត្រូវចងសេចក្តីទាំងនេះជាប់នៅដៃឯង ទុកជាទីសំគាល់ ហើយត្រូវធ្វើជាស្លាកនៅកណ្តាលថ្ងាសឯងផង(ចោទិយកថា ៦:៥-៨)។*

ព្រះគម្ពីរបានប្រាប់យើងថា ក្នុងនាមជាឪពុកម្តាយ កិច្ចការសំខាន់បំផុតដែលយើងត្រូវធ្វើសម្រាប់កូនយើង គឺត្រូវបង្រៀនពួកគេឲ្យស្រឡាញ់ព្រះអម្ចាស់ ឲ្យអស់ពីចិត្ត ពីវិញ្ញាណ និងកម្លាំង។ នេះជាគោលដៅធំបំផុតដែលឪពុកម្តាយមានសម្រាប់កូន គឺមិនត្រូវយកការព្រួយបារម្ភណាមួយ ជាគោលដៅដែលសំខាន់ជាងនេះឡើយ ទោះវាជាការព្រួយបារម្ភ អំពីការរៀនសូត្ររបស់ពួកគេក៏ដោយ។

ជារៀងរាល់ថ្ងៃ តើធ្វើដូចម្តេច ឲ្យយើងអាចបង្រៀនកូន ឲ្យស្រឡាញ់ព្រះ?

## ចាត់ទុកព្រះជាសំខាន់ជាងការព្រួយបារម្ភ អំពីការរៀនសូត្ររបស់កូន

គឺមានន័យថា យើងយកព្រះជាទីមួយ នៅក្នុងការប្រើប្រាស់ពេលវេលា និងធនធានរបស់យើង។ ឧទាហរណ៍ យើងអាចចែកចាយរឿងដំណឹងល្អ ដល់កូន

របស់យើង គឺមិនមែនតែម្តង តែជាទៀងទាត់។ យើងចាំបាច់ត្រូវបង្រៀនពួកគេឲ្យដឹងថា ព្រះជានរណា ព្រះអង្គបានធ្វើអ្វីខ្លះសម្រាប់យើង និងប្រាប់អំពីផលវិបាកនៃអំពើបាប ភាពចាំបាច់នៃការប្រែចិត្ត និងព្រះគុណដ៏ជួយសង្គ្រោះរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ការបង្រៀនកូនយើងឲ្យស្រឡាញ់ព្រះយេស៊ូវ គឺស្ថិតក្នុងចំណោមកំណប់ទ្រព្យខាងវិញ្ញាណដែលមានតម្លៃបំផុត ដែលយើងអាចបន្សល់ទុកឲ្យកូនយើង។ យើងគួរតែអធិស្ឋានឲ្យ និងជាមួយកូនៗរបស់យើង ជាទៀតទាត់ គឺអធិស្ឋានអំពីផ្នែកនីមួយៗនៃជីវិត ហើយបង្រៀនពួកគេ អំពីគោលតម្លៃដែលគោរពប្រតិបត្តិដល់ព្រះ ដែលពួកគេអាចរកបាន តាមរយៈការរៀនព្រះគម្ពីរជាលក្ខណៈគ្រួសារ ការបម្រើព្រះជាមួយគ្នា នៅព្រះវិហារ និងការធ្វើជាគំរូល្អ។ ការយកព្រះជាទីមួយ គឺមានន័យថា យើងបែងចែក និងរក្សាពេលវេលា និងកម្លាំងរបស់យើង ដើម្បីការលូតលាស់ខាងវិញ្ញាណរបស់យើង និងកូនៗរបស់យើង ដោយមិនបណ្តោយឲ្យការរៀនសូត្ររបស់កូនយើង មានភាពសំខាន់ជាងអាទិភាពខាងវិញ្ញាណរបស់យើងនោះឡើយ។

## ចំណាយពេលនឹកចាំ អំពីព្រះ

ការយកព្រះជាទីមួយ ក៏មានន័យថា យើងធ្វើយ៉ាងណា ឲ្យកូនយើងមានពេលវេលា នឹកចាំអំពីព្រះអង្គ។ យើងចាំបាច់ត្រូវជួយពួកគេ ឲ្យប្តេជ្ញាចិត្តលះបង់ពេលវេលា ដើម្បីសិក្សាអំពីព្រះ និងប្រកបជាមួយរាស្ត្ររបស់ព្រះអង្គ ក្នុងពួកជំនុំជាជាងជំរុញពួកគេឲ្យរៀនបន្ថែម នៅចុងសប្តាហ៍។ ការនេះហាក់ដូចជាពិបាកធ្វើ។ ប៉ុន្តែ នេះជាផ្នែកមួយនៃផែនការ ដែលព្រះជាម្ចាស់មានសម្រាប់ស្នាព្រះហស្តទាំងអស់របស់ព្រះអង្គ។ ការលូតលាស់ និងភាពស្រស់ថ្លាខាងវិញ្ញាណ គឺជាធាតុផ្សំដ៏សំខាន់ ក្នុងការធ្វើដំណើរខាងវិញ្ញាណរបស់យើង។

ទោះជាយ៉ាងណាក៏ដោយ យើងត្រូវចាំថា ការទទួលខុសត្រូវចំពោះការលូតលាស់ខាងវិញ្ញាណរបស់កូនយើង គឺមិនពឹងផ្អែកទៅលើពួកជំនុំនោះឡើយ។ ព្រោះបទគម្ពីរ ដូចជា សុភាសិត ២២:៦ និង ចោទិយកថា ៦:៥-៨ សុទ្ធតែបាននិយាយសំដៅទៅលើឪពុកម្តាយតែម្តង។

បទគម្ពីរទាំងពីរក៏បានបង្ហាញថា យើងត្រូវតែបង្រៀនកូនៗរបស់យើងផងដែរ។

ព្រះជាម្ចាស់បានប្រទានឲ្យយើងមានភារកិច្ចបង្រៀនកូនៗរបស់យើង អំពីសេចក្ដីខាងវិញ្ញាណដ៏បរិសុទ្ធ ជាសំខាន់បំផុត គឺសំខាន់ជាងការរៀនសូត្ររបស់ពួកគេ។ មានមតិមួយបានពោលថា "បើយើងមិនបង្រៀនកូនៗយើង ឲ្យស្រឡាញ់ព្រះយេស៊ូវទេ លោកិយនឹងបង្រៀនពួកគេមិនឲ្យស្រឡាញ់ព្រះអង្គមិនខាន"។ នៅក្នុងសម័យដែលមានការប្រកួតប្រជែងខ្លាំង ក្នុងការរៀនសូត្រ អាទិភាពទីមួយរបស់យើង គឺត្រូវបង្រៀនកូនយើង ឲ្យស្គាល់ និងស្រឡាញ់ព្រះអង្គ។

អ្នកខ្លះប្រហែលជាមានអារម្មណ៍ថា ការមើលការខុសត្រូវមកលើការលូតលាស់ខាងវិញ្ញាណ របស់កូនៗយើង គឺជាការតម្រូវដ៏ពិបាកមួយ។ ប៉ុន្តែ ព្រះមិនបានប្រទានកិច្ចការនេះមកយើង ដោយមិនបានប្រទានឲ្យយើងមានលទ្ធភាពធ្វើវានោះឡើយ។ ពេលណាយើងចូលទៅជិតព្រះអង្គ ដើម្បីថ្វាយការភ័យខ្លាច និងការព្រួយបារម្ភ ហើយពេលណាយើងលូតលាស់ នៅក្នុងការដើរជាមួយព្រះអង្គ នោះព្រះអង្គនឹងជួយឲ្យយើងអាចបំពេញភារៈកិច្ចដ៏បរិសុទ្ធរបស់យើង ដោយបង្រៀនកូនៗយើង ឲ្យស្គាល់ និងស្រឡាញ់ព្រះអង្គជារៀងរាល់ថ្ងៃ សូម្បីតែតាមរយៈកំហុសរបស់យើងក៏ដោយ។

**ការពិចារណា**

១. តើមានវិធីសាស្ត្រអ្វីខ្លះ ដែលខ្ញុំអាចប្រើ ដើម្បីសង្កត់ធ្ងន់អំពីការកោតខ្លាចព្រះឲ្យខ្លាំងជាងជោគជ័យក្នុងការរៀនសូត្ររបស់កូន?

២. តើខ្ញុំអាចរំលែក និងរក្សាពេលវេលាយ៉ាងដូចម្ដេច ដើម្បីចែកចាយដំណឹងល្អ ការអធិស្ឋាន និងការថ្វាយបង្គំព្រះជាមួយកូនរបស់ខ្ញុំ?

៣. តើធ្វើដូចម្ដេច ឲ្យគ្រួសារខ្ញុំអាចដាក់អាទិភាព ទៅលើការជួបជាមួយរាស្ត្ររបស់ព្រះ?

## ចូរកុំរសាយចិត្ត ប៉ុន្តែ ចូរយកគំរូតាមសេចក្ដីស្រឡាញ់របស់ព្រះ

ការបង្រៀនកូនៗរបស់យើងឲ្យស្រឡាញ់ព្រះ ក៏មានន័យថា យើងមានទំនាក់ទំនងជាមួយពួកគេ ស្របតាមការបង្រៀនរបស់ព្រះជាម្ចាស់ គឺដូចមានសេចក្ដីចែងថា:

*ឪពុករាល់គ្នាអើយ កុំឲ្យចាក់រុកកូនរបស់ខ្លួនឡើយ ចូរបង្រៀនវាទៅតាម*

*ដំបូន្មាន និងសេចក្ដីដាស់តឿនរបស់ព្រះអម្ចាស់វិញ។ អេភេសូរ ៦:៤*

ត្រង់ចំណុចនេះ សាវ័កប៉ុលបានលើកទឹកចិត្តយើង ឲ្យគិតដល់សុខុមាលភាពផ្លូវចិត្ត និងផ្លូវអារម្មណ៍របស់កូនៗយើងផងដែរ។ តែយើងងាយនឹងភ្លេចរឿងនេះ នៅក្នុងសម័យដែលមានការប្រកួតប្រជែងខ្លាំង ក្នុងការរៀនសូត្រ។

*ហ្គារេត(Gareth)ជាក្មេងអាយុ១០ឆ្នាំ។ ថ្ងៃមួយ ហ្គារេតបានវិលត្រឡប់មកផ្ទះវិញ ដោយនាំក្រដាស់ពិន្ទុះប្រឡង មកឲ្យលោកយ៉ាកុប(Jacob)ដែលឪពុករបស់គាត់។ លោកយ៉ាកុបក៏បានស្រែកដាក់គាត់ថា "កូនរៀនយ៉ាងម៉េច បានពន្ទុះអន់យ៉ាងនេះ?" លោកយ៉ាកុបក៏បានគំរាមគាត់ថា "តើកូនពិតជាល្ងង់យ៉ាងនេះឬ? យកល្អ កូនគួរតែខំរៀនឲ្យខ្លាំងជាងនេះទៀត!" ហ្គារេតក៏បានស្រក់ទឹកភ្នែក។*

ពេលណាយើងមានការរំពឹងចង់បាន ដែលមិនសមហេតុផល មកលើកូនៗរបស់យើង ឬមានការសង្កត់ធ្ងន់ដាច់ខាត មកលើលទ្ធផលនៃការសិក្សារបស់ពួកគេ គឺមានន័យថា យើងកំពុងតែបង្កើតឲ្យមានអារម្មណ៍ ដែលត្រូវគេបដិសេធ នៅក្នុងចិត្តរបស់ពួកគេ ដែលអាចនាំឲ្យមានភាពល្វីងជូរចត់ ឬកំហឹង។ ប៉ុន្តែ ព្រះបន្ទូលព្រះបានរំឭកយើងថា : កុំឲ្យចាក់រុកកូនរបស់ខ្លួនឲ្យមានកំហឹង។ កុំធ្វើឲ្យពួកគេមានចិត្តជូរល្វីង។ កុំធ្វើឲ្យពួកគេមានអារម្មណ៍ថា ត្រូវបានគេបដិសេធន៍នោះឡើយ។

ផ្ទុយទៅវិញ ព្រះអង្គបានត្រាស់ហៅយើង ឲ្យត្រាប់តាមព្រះអង្គ ដោយស្រឡាញ់កូន និងមានសេចក្ដីមេត្តាចំពោះពួកគេ។ សេចក្ដីស្រឡាញ់ដែលយើងមានចំពោះកូនយើង គឺមិនត្រូវមានលក្ខខណ្ឌ និងផ្អែកទៅលើលទ្ធផលនៃការសិក្សារបស់ពួកគេនោះឡើយ ដ្បិតព្រះអង្គស្រឡាញ់យើង ដោយគ្មានលក្ខខណ្ឌ។ ផ្ទុយទៅវិញ យើងត្រូវមានចិត្ត "ប្រកបដោយមេត្តាករុណា និងអាណិតអាសូរ … យឺតនឹងខឹង ហើយមានសេចក្ដីសប្បុរស និងសេចក្ដីពិតត្រង់ជាបរិបូរ"(ទំនុកដំកើង ៨៦:១៥)។

ក្នុងនាមយើងជាអ្នកទទួលព្រះគុណព្រះ តើយើងកំពុងតែបង្ហាញចេញនូវព្រះ

គុណ ចំពោះកូនរបស់យើង យ៉ាងដូចនេះ នៅក្នុងសម័យដែលមានការប្រកួតប្រជែងខ្លាំង ក្នុងការសិក្សាឬទេ?

## ការពិចារណា

១. តើខ្ញុំត្រូវធ្វើដូចម្តេច ដើម្បីការពារសុខុមាលភាពផ្លូវចិត្ត និងអារម្មណ៍របស់កូនខ្ញុំ និងមិនបន្ថែមស្ត្រេសដល់ពួកគេ?

២. តើខ្ញុំបានបង្ហាញឲ្យកូនខ្ញុំដឹងថា ខ្ញុំនឹងស្រឡាញ់ពួកគេតិចជាងមុខ បើសិនជាពួកគេរៀនមិនពូកែឬ? តើធ្វើដូចម្តេចឲ្យខ្ញុំអាចធ្វើឲ្យពួកគេជឿជាក់ថា ខ្ញុំនឹងស្រឡាញ់ពួកគេ ទោះពួកគេបានទទួលលទ្ធផលក្នុងការសិក្សា យ៉ាងណាក៏ដោយ?

៣. តើខ្ញុំអាចបង្ហាញសេចក្តីស្រឡាញ់ និងសេចក្តីមេត្តារបស់ព្រះ ដល់កូនខ្ញុំ យ៉ាងដូចម្តេច ជារៀងរាល់ថ្ងៃ? តើត្រូវបង្ហាញដោយសកម្មភាព ពាក្យសម្តី និងអារម្មណ៍យ៉ាងដូចម្តេចខ្លះ?



*ទី៣*

# ការរៀនសូត្រ គឺជាការរៀនអំពីព្រះ និងស្គាល់ព្រះហស្តព្រះអង្គ

**តើហេតុអ្វីបានជាឪពុកម្តាយទាំងឡាយស្ត្រេសខ្លាំងយ៉ាងនេះ** ក្នុងសម័យប្រណាំងប្រជែង ក្នុងការរៀនសូត្រ?

ត្រង់ចំណុចនេះ អ្នកខ្លះចង្អុលបង្ហាញថា ឪពុកម្តាយទាំងឡាយមានស្ត្រេសខ្លាំងយ៉ាងនេះ ដោយសារពួកគេកំពុងតែរស់នៅក្នុងសង្គម ដែលចូលចិត្តធ្វើអ្វីលឿនៗ និងមានការប្រកួតប្រជែងខ្លាំង ដោយមានស្តង់ដាខ្ពស់ៗ ហើយម្នាក់ៗប្រកួតប្រជែង ដើម្បីឲ្យបានដល់ចំណុចខ្ពស់ជាងគេ។ ក្មេងៗទទួលរងសម្ពាធខ្លាំង ដែលជំរុញឲ្យពួកគេរៀនឲ្យបានពន្ទុះល្អឥតខ្ចោះ និងឡើងឲ្យដល់កំពូល ហើយបានចូលរៀនសាលាល្អជាងគេ ដើម្បីឲ្យមានការជឿជាក់ថា ពួកគេនឹងរកបានការងារល្អ នៅពេលពួកគេធំឡើង។

អ្នកខ្លះទៀតបានចង្អុលបង្ហាញថា ឪពុកម្តាយទាំងឡាយមានស្ត្រេសខ្លាំង គឺដោយសារសាលារៀនបានបន្តបង្កើនស្តង់ដានៃការអប់រំ កាន់តែខ្ពស់ឡើងៗ។ លោកឌីនេស(Dinesh) ដែលជាឪពុករបស់ជូលា(Julia) ដែលជាក្មេងអាយុ៨ឆ្នាំ បានលាន់មាត់ថា "លំហាត់គណិតវិទ្យាឥឡូវពិបាកៗណាស់។ ខ្ញុំមើលលំហាត់របស់កូនស្រីខ្ញុំមិនយល់ទេ!" ទន្ទឹមនឹងនោះ ឪពុកម្តាយដទៃទៀត បាននិយាយថា កម្មវិធីសិក្សាសម័យឥឡូវ បានធ្វើឲ្យសិស្សកាន់តែពិបាករៀនដោយខ្លួនឯងនៅផ្ទះ។ អ្នកស្រីស៊ូជីង(Su Ching) ជាម្តាយរបស់អេលាត ដែលមានអាយុ ១២ឆ្នាំ។

គាត់និយាយថា "វិញ្ញាណសារប្រឡងមានលំហាត់ និងសំណួរដែលគ្រូមិនបាន បង្រៀនក្នុងថ្នាក់រៀន។ ហេតុនេះហើយបានជាក្មេងៗចាំបាច់ត្រូវរៀនគួរច្រើនយ៉ាងនេះ"។

យើងមិនអាចប្រកែកបានឡើយថា មនុស្សភាគច្រើនមិនអាចធ្វើអ្វីបានច្រើន ដើម្បីផ្លាស់ប្តូរសង្គម ដែលយើងកំពុងតែរស់នៅ។ មានកត្តាខាងក្រៅជាច្រើន ដែលនាំឲ្យយើងមានស្ត្រេស ក្នុងកំរិតណាមួយ។

ប៉ុន្តែ ព្រះគម្ពីរបានបញ្ជាក់ច្បាស់ថា ចិត្តដែលមានអំពើបាប គឺជាកត្តាធំជាងគេ ដែលនាំឲ្យយើងមានស្ត្រេសខ្លាំងយ៉ាងនេះ។

## តើការសិក្សារបស់កូនបានក្លាយជារូបព្រះ ដែលយើងកំពុងតែថ្វាយបង្គំឬ?

*ក៏រហ័សងាកបែរចេញពីផ្លូវដែលអញបានបង្គាប់គេ ហើយបានសិតធ្វើរូបកូនគោនាំគ្នាក្រាបថ្វាយបង្គំដល់រូបនោះ(និក្ខមនំ ៣២:៨)។*

ពេលយើងអានបទគម្ពីរ ដែលនិយាយអំពីពួកអ៊ីស្រាអែល ដែលកំពុងតែថ្វាយបង្គំរូបចម្លាក់កូនគោ ដែលពួកគេបានសូនពីមាស យើងប្រហែលជានិយាយក្នុងចិត្តថា "ខ្ញុំនឹងមិនថ្វាយបង្គំរូបកូនគោមាសជាដាច់ខាត!" ប៉ុន្តែ តើយើងដឹងទេថា សព្វថ្ងៃនេះ មានរូបកូនគោជាច្រើនប្រភេទ ដែលយើងមើលមិនឃើញ? តើយើងដឹងទេថា សព្វថ្ងៃនេះ រូបកូនគោនោះកំពុងតែចាំពួនឆ្មក់ នៅក្នុង ចិត្ត និង គំនិតរបស់យើង?

របស់ដែលយើងធ្វើឲ្យក្លាយជារូបព្រះ មិនសុទ្ធតែជារបស់អាក្រក់នោះទេ។ វាអាចជារបស់ល្អ ដែលយើងបានធ្វើឲ្យក្លាយជារបស់ដែលធំបណ្តាច់ ។ វាអាចជាគោលដៅដ៏ត្រឹមត្រូវ ដែលយើងប្រហែលជាបានធ្វើឲ្យក្លាយជាគោលដៅធំបណ្តាច់។ ក្នុងខ្លួនយើង តែងតែមានការប្រទាញប្រទង់គ្នា ដោយសារចិត្តដែលមានអំពើបាប និងថ្វាយបង្គំរូបព្រះ ដែលចង់សម្រេចគោលដៅល្អៗ ដូចជាជោគជ័យក្នុងការអប់រំ ឬចង់ឲ្យកូនយើងមានអនាគតល្អជាដើម ហើយក៏បានធ្វើឲ្យគោលដៅនេះ ក្លាយជាគោលដៅធំជាងគេ ដែលត្រូវខិតខំសម្រេចឲ្យបាន ទោះត្រូវមានលះបង់យ៉ាងណាក៏ដោយ។

ពេលណាយើងធ្វើឲ្យការអប់រំរបស់កូន ក្លាយជារូបព្រះរបស់យើង យើងនឹងមានកំហឹងដែលមិនសមហេតុផល ពេលណាកូនៗរបស់យើងបរាជ័យក្នុងការសិក្សា ឬយើងមានមោទនភាពជ្រុល ពេលដែលពួកគេជោគជ័យ។ ពេលណាយើងយកការអប់រំរបស់កូនជារូបព្រះ យើងនឹងមានការថប់បារម្ភ ឬមានទំនុកចិត្តជ្រុល ពេលយើងប្រៀបធៀនកូនយើង ជាមួយកូនអ្នកដទៃ។ ពេលណាយើងយកការអប់រំ ធ្វើជារូបព្រះរបស់យើង យើងនឹងធ្វើឲ្យវាក្លាយជាអាទិភាពទីមួយ ក្នុងជីវិតយើង ដោយធ្វើយ៉ាងណាឲ្យកូនយើងមានជោគជ័យ ទោះការធ្វើដូចនេះ ធ្វើឲ្យខូចអាទិភាពខាងវិញ្ញាណរបស់យើងក៏ដោយ។

យើងមិនអាចបម្រើទាំងរូបព្រះផង និងព្រះផងបានទេ។ ព្រះយេស៊ូវបានមានបន្ទូលច្បាស់ថា យើងមិនអាចបម្រើម្ចាស់ពីរបានឡើយ។ គឺដូចដែលព្រះអង្គបានមានបន្ទូលថា "គ្មានអ្នកណាអាចនឹងបំរើចៅហ្វាយ២នាក់បានទេ ដ្បិតអ្នកនោះនឹងស្អប់១ ហើយស្រឡាញ់១ ឬស្មោះត្រង់នឹង១ ហើយមើលងាយ១ អ្នករាល់គ្នាពុំអាចនឹងគោរពដល់ព្រះ និងទ្រព្យសម្បត្តិផងបានទេ"(ម៉ាថាយ ៦:២៤)។ តាមព្រះបន្ទូលព្រះយេស៊ូវ យើងមិនអាចបម្រើព្រះ និងលុយ ធ្វើជាម្ចាស់ក្នុងពេលតែមួយបានទេ។ ហើយផ្អែកទៅលើគោលការជាមូលដ្ឋាននេះ លោកហ្វ្រង់ស៊ីស បេខិន (Francis Bacon) ធ្លាប់មានប្រសាសន៍ថា "លុយ គឺជាអ្នកបម្រើដ៏អស្ចារ្យ តែជាចៅហ្វាយនាយដ៏អាក្រក់"។ ដូចនេះ យើងក៏អាចនិយាយផងដែរថាៈ "ការអប់រំ គឺជាអ្នកបម្រើដ៏ល្អ តែជាចៅហ្វាយនាយដ៏អាក្រក់"។

តើការអប់រំ និងបំណងចិត្តរបស់យើង ដែលចង់ឲ្យកូនយើងជោគជ័យ បានក្លាយជារូបព្រះហើយឬ?

ចិត្តរបស់យើងងាយនឹងបញ្ឆោះបញ្ឆូលយើង ឲ្យជឿថា យើងមិនមានរូបព្រះទាល់តែសោះ ក្នុងពេលបច្ចុប្បន្ន។ តែ ព្រះគម្ពីរបានរំឭកយើងថា "ឯចិត្តជាគ្រឿងបញ្ឆោតលើសជាងទាំងអស់ ហើយក៏អាក្រក់ហួសល្បត់ផង តើអ្នកណានឹងអាចស្គាល់បាន"(យេរេមា ១៧:៩)។

ព្រះបានត្រាស់ហៅរាស្ត្រព្រះអង្គ ឲ្យគេចចេញពីការថ្វាយបង្គំរូបព្រះ ហើយត្រូវថ្វាយបង្គំព្រះអង្គតែមួយប៉ុណ្ណោះ។ នេះជាដំណើរការដែលប្រព្រឹត្តទៅពេញមួយជីវិតយើង ដែលចាប់ផ្តើម ពេលណាដែលយើងទូលសូមព្រះ ឲ្យបើកបង្ហាញ

អំពើបាបរបស់យើង ឲ្យយើងបានដឹង គឺដូចដែលស្ដេចដាវីឌបានទូលសូម ក្នុងបទគម្ពីរទំនុកដំកើង ១៣៩:២៣-២៤ ថា : ‶ឱព្រះអង្គអើយ សូមពិនិត្យមើល ឲ្យបានស្គាល់ចិត្តទូលបង្គំផង សូមល្បងលឲ្យបានជ្រាបអស់ទាំងគំនិតនៃទូលបង្គំចុះ សូមទតមើលបើមានអំពើអាក្រក់ណានៅក្នុងទូលបង្គំ ហើយនាំទូលបង្គំតាមផ្លូវដ៏នៅអស់កល្បជានិច្ច″។

## ការពិចារណា

១. តើមានរូបព្រះអ្វីខ្លះ ដែលបានចងរឹតចិត្តរបស់ខ្ញុំ ក្នុងសម័យដែលមានការប្រណាំងប្រជែងខ្លាំង ក្នុងការអប់រំ?

២. តើធ្វើដូចម្ដេច ឲ្យខ្ញុំអាចងាកចេញពីរូបព្រះរបស់ខ្ញុំ ហើយចុះចូលនឹងព្រះជារៀងរាល់ថ្ងៃ?

# តើយើងអាចផ្លាស់ប្ដូរទស្សនៈ ចំពោះការអប់រំឬទេ?

យើងអាចឈប់យកការអប់រំ ធ្វើជារូបព្រះ តែការប្រណាំងប្រជែង ក្នុងការអប់រំ កម្មវិធីសិក្សា និងការប្រឡង នឹងនៅតែមានដដែល។ ប៉ុន្តែ យើងអាចផ្លាស់ប្ដូរទស្សនៈដែលយើងមានចំពោះការអប់រំ និងផ្លាស់ប្ដូររបៀបដែលយើងដោះស្រាយបញ្ហាស្រេ្តសទាំងនេះ។

ពេលដែលអេម៉ុស(Amos) ដែលជាក្មេងអាយុ១៤ឆ្នាំ ត្រឡប់ពីសាលារៀនវិញ សំណួរទីមួយ ដែលអ្នកស្រីចេននីហ្វ័រ(Jennifer) បានសួរគាត់គឺ ‶តើកូនមានកិច្ចការគ្រូដាក់ឲ្យធ្វើនៅផ្ទះទេ?″ សព្វថ្ងៃនេះ អ្នកស្រីចេនីហ្វ័របានសួរសំណួរផ្សេងពីនេះថា ‶តើកូនរៀនបានអ្វីខ្លះ ពីស្នាព្រះហស្តរបស់ព្រះ នៅថ្ងៃនេះ?″ ពេលដែលអ្នកស្រីចេនីហ្វ័រសួរសំណួរនេះជាលើកទីមួយ អាម៉ុសបានផ្ទុះសំណើច ហើយឆ្លើយតបថា ‶ហេតុអី ម៉ាក់សួរកូនអញ្ចឹង? កូនរៀនមុខវិជ្ជាភាសាអង់គ្លេស ចិន គណិតវិទ្យា ជីវវិទ្យា គីមីវិទ្យា និងប្រវត្តិសាស្ត្រ នៅសាលារៀន! យើងរៀនអំពីព្រះ តែនៅថ្ងៃអាទិត្យទេ″។ ម្ដាយរបស់គាត់ក៏បានញញឹម ហើយនិយាយថា ‶ទេ អេម៉ុស មុខវិជ្ជាទាំងអស់នោះ គឺសុទ្ធតែនិយាយ អំពីស្នាព្រះហស្តរបស់ព្រះ!″

ការអប់រំបានផ្តល់ឱកាសដ៏មានតម្លៃ ឲ្យយើងស្ញើចសរសើរចំពោះស្នាព្រះហស្តរបស់ព្រះ និងចំពោះព្រះអង្គ ដែលជាព្រះអាទិករ។ គឺដូចដែលបទគម្ពីរទំនុកដំកើង ១៩:១-២ បានចែងថា "ផ្ទៃមេឃសំដែងពីសិរីល្អនៃព្រះ

ហើយលំហអាកាសក៏បង្ហាញការ ដែលព្រះហស្តទ្រង់ធ្វើ ថ្ងៃ១ពោលប្រាប់តដល់ថ្ងៃ១ទៀត ហើយយប់១ក៏សំដែងចំណេះដល់យប់១ទៀតដែរ"។

មុខវិជ្ជាទាំងអស់នៅសាលា សុទ្ធតែបានផ្តល់ឱកាសឲ្យយើងសិក្សាបន្ថែមអំពីព្រះ។ តាមរយៈភាសា យើងអាចរៀន អំពីភាពចម្រុះនៃពូជសាសន៍ និងវប្បធម៌ ដែលព្រះបានអនុញ្ញាតឲ្យចម្រើនឡើង ទូទាំងពិភពលោក។ តាមរយៈគណិតវិទ្យា និងវិទ្យាសាស្ត្រ យើងរៀនសូត្រអំពីសណ្តាប់ធ្នាប់ នៃស្នាព្រះហស្តរបស់ព្រះ និងអំពីរបៀបដែលព្រះបានរៀបចំ និងលម្អស្នាព្រះហស្តទាំងនោះ។ ការសិក្សាអំពីរុក្ខជាតិ និងសត្វ ក្នុងជីវវិទ្យា បានចង្អុលបង្ហាញឲ្យយើងងាកទៅរករបៀបដែលព្រះអង្គបានបង្កើតជីវិតទាំងឡាយមក។ ការសិក្សាប្រវត្តិសាស្ត្របានចង្អុលបង្ហាញ អំពីភាពថ្លៃថ្នូ និងអំពើបាបរបស់មនុស្សជាតិ។ ហើយមុខវិជ្ជាជាច្រើនទៀត ក៏បានសិក្សា អំពីស្នាព្រះហស្តរបស់ព្រះផងដែរ។

ព្រះជាវិចិត្រករ តន្ត្រីករ គណិតវិទូ អ្នកវិទ្យាសាស្ត្រ វិស្វករ ។ល។ និយាយឲ្យខ្លី ការអប់រំគឺមិនគ្រាន់តែដើម្បីឲ្យបានពន្ទុះតែប៉ុណ្ណោះឡើយ តែក៏ត្រូវស្វែងយល់អំពីព្រះផងដែរ។

ពេលណាយើងជំរុញកូនយើង ឲ្យខំរៀនយកពន្ទុះឲ្យបានល្អតែម្យ៉ាង នោះយើងអាចបាត់បង់ឱកាសជួយពួកគេ ឲ្យស្វែងយល់ អំពីស្នាព្រះហស្តរបស់ព្រះ និងងាកទៅរកព្រះអង្គ តាមរយៈការស្វែងយល់ អំពីស្នាព្រះហស្តព្រះអង្គ។ ពេលណាយើងយល់ឃើញថា ការរៀនសូត្រគ្រាន់តែជាការអង្គុយរៀនមេរៀន យើងបាត់បង់ឱកាសផ្តល់ឲ្យកូនយើង នូវមេរៀនដែលល្អបំផុត ដែលបង្រៀនថា ព្រះជាម្ចាស់លើស្នាព្រះហស្តទាំងអស់ ហើយក៏ជាម្ចាស់នៃការប្រណាំងប្រជែង ក្នុងការអប់រំផងដែរ។

# ការពិចារណា

១. តើខ្ញុំកំពុងតែនាំឲ្យកូនខ្ញុំគិតថា ការអប់រំ គឺគ្រាន់តែជាការរៀនដើម្បីឲ្យបានពិន្ទុល្អឬ?

២.ធ្វើដូចម្ដេច ឲ្យខ្ញុំអាចមានការសន្ទនាកាន់តែមានន័យ ជាមួយកូនៗរបស់ខ្ញុំ ហើយជួយពួកគេ ឲ្យដឹងថា ការអប់រំ ក៏ជាការស្វែងយល់អំពីស្នាព្រះហស្ត និងអំពីព្រះផងដែរ?



*ទី៤*

# ការសម្រាក ក្នុងច្បាប់របស់ព្រះ

**មានពេលមួយ អ្នកស្រីដន(Dawn) បានឈ្លោកមុខ។** កូនប្រុសរបស់គាត់ឈ្មោះម៉ាក អាយុ៩ឆ្នាំ មានការធ្វេសប្រហែស នៅក្នុងការប្រឡងមុខវិជ្ជាភាសាអង់គ្លេស ហើយក៏បាននិទ្ទេស "B" នៅពេលដែលគាត់អាចយកបាននិទ្ទេស "A"។ អ្នកស្រីដន មានការថប់បារម្ភ ប៉ុន្តែ គាត់បាននឹកចាំ អំពីព្រះបន្ទូលព្រះ ក្នុងបទគម្ពីរ រ៉ូម ១២:២។ គាត់ក៏បានបន្លឺសម្លេងអធិស្ឋានថា "ទូលបង្គំមិនចង់ត្រាប់តាមសម័យនេះឡើយ តែចង់ផ្លាស់ប្រែ ដោយគំនិតបានកែជាថ្មីឡើង" ឱព្រះអម្ចាស់ ទូលបង្គំមិនចង់មានប្រតិកម្មជ្រុលពេក ចំពោះកូនរបស់ទូលបង្គំទេ។ ប៉ុន្តែទូលបង្គំមិនចង់ឲ្យកូនទូលបង្គំបន្តមានការធ្វេសប្រហែសទៀតឡើយ។ តើទូលបង្គំគួរតែធ្វើយ៉ាងណា?"

តើការទទួលស្គាល់ថា ព្រះទ្រង់ជាម្ចាស់នៃការប្រណាំងប្រជែង ក្នុងការអប់រំ មានន័យដូចម្តេច ចំពោះយើង?

តើវាជាការអធិស្ឋានឲ្យកូនរបស់យើង ហើយឈប់រវីរវល់រឿងរៀនសូត្ររបស់ពួកគេឬ? ត្រង់ចំណុចនេះ ព្រះគម្ពីរបានផ្តល់ឲ្យនូវប្រាជ្ញា សម្រាប់ឲ្យយើងអនុវត្តខុសពីនេះ។ មានវិធីជាច្រើន ដែលយើងអាចជួយកូនៗរបស់យើង ឲ្យដាក់ព្រះនៅក្នុងចំណុចកណ្តាលនៃការប្រណាំងប្រជែង ក្នុងការអប់រំរបស់ពួកគេ។

## គឺមានន័យថា យើងត្រូវសិក្សាព្រះគម្ពីរ

*ការអ្វីដែលត្រូវធ្វើក៏ដោយ ចូរធ្វើឲ្យអស់ពីចិត្ត ទុកដូចជាធ្វើថ្វាយដល់ព្រះអម្ចាស់ មិនមែនដល់មនុស្សទេ(កូល៉ុស ៣:២៣)។*

សព្វថ្ងៃនេះ កូនៗរបស់យើង មានមុខរបរជាសិស្ស។ ដូចនេះ យើងអាចលើកទឹកចិត្តពួកគេ ដោយបង្ហាញពួកគេឲ្យដឹងថា ពួកគេមានគោលបំណងដែលមានន័យជាងការសិក្សា ដែលគ្រាន់តែដើម្បីឲ្យបានពិន្ទុខ្ពស់ជាងគេ។ ត្រង់ចំណុចនេះ តាមព្រះបន្ទូលព្រះ ពួកគេត្រូវរៀនសូត្រ ដើម្បីព្រះអម្ចាស់។

ចូរកត់សំគាល់ថា : កូនរបស់យើង មិនត្រូវរៀនសូត្រ ដើម្បីយើង ឬដើម្បីសម្រេចបំណងរបស់យើងនោះទេ។ ហើយពួកគេក៏មិនត្រូវរៀនសូត្រ ដើម្បីខ្លួនឯង ឬដើម្បីឲ្យខ្លួនឯងរុងរឿងនោះដែរ។ ផ្ទុយទៅវិញ គោលដៅធំបំផុតរបស់ពួកគេ ក្នុងការរៀនសូត្រ គឺត្រូវថ្វាយសិរីល្អដល់ព្រះ។

បើកូនយើងរៀននៅសាលា បានពន្ទុះល្អ យើងប្រហែលជាចង់មានមោទនៈភាព ឬចង់សរសើរសមត្ថភាពរបស់ពួកគេ។ ប៉ុន្តែ គឺព្រះទេ ដែលសក្តិសមនឹងទទួលការលើកសរសើរ។ និយាយរួម ព្រះអង្គបានបង្កើតកូនៗរបស់យើងមក និងបានប្រទានឲ្យពួកគេមានសមត្ថភាព។

ហើយបើពួកគេមានបញ្ហាក្នុងការរៀនសូត្រ យើងត្រូវងាកទៅរកព្រះ ជាមួយកូនៗយើង មុនយើងងាកទៅរកមនុស្សណាម្នាក់ ព្រោះព្រះអង្គជាប្រភពនៃកម្លាំង និងប្រាជ្ញារបស់យើង។

យើងមិនគួរឲ្យតម្លៃកូនរបស់យើង ដោយផ្អែកទៅលើនិទ្ទេសរបស់ពួកគេឡើយ។ ផ្ទុយទៅវិញ ពួកគេគួរទទួលយកតម្លៃ ដែលព្រះប្រទាន ព្រោះព្រះអង្គជាព្រះដែលមានក្តីស្រឡាញ់ និងសព្វព្រះទ័យនឹងមានទំនាក់ទំនងជាមួយពួកគេផ្ទាល់ៗខ្លួន ហើយបានបង្កើតពួកគេម្នាក់ៗមក ឲ្យមានលក្ខណៈពិសេសរៀងៗខ្លួន ព្រមទាំងមានផែនការ សម្រាប់កូនរបស់ព្រះអង្គទាំងអស់ ទោះពួកគេបានទទួលពិន្ទុះប៉ុន្មានក៏ដោយ ក្នុងការប្រឡង។

សូមយើងចងចាំចំណុចនេះ ដើម្បីឲ្យយើងនៅតែមានទស្សនៈត្រឹមត្រូវ ពេលដែល

កូនរបស់យើងបានទទួលលទ្ធផលក្នុងការប្រឡង តិចជាងការរំពឹងចង់បានរបស់យើង។

## ការពិចារណា

១. តើខ្ញុំអាចលើកទឹកចិត្តកូនខ្ញុំយ៉ាងដូចម្ដេច ដើម្បីឲ្យកុំពួកគេរៀនសូត្រ ដើម្បីខ្ញុំ ឬដើម្បីលើកដំកើងខ្លួនឯង តែដើម្បីថ្វាយសិរីល្អដល់ព្រះ ដែលនេះជាគោលបំណងដែលធំជាង?

២. តើខ្ញុំអាចជួយកូនខ្ញុំយ៉ាងដូចម្ដេច ដើម្បីឲ្យពួកគេជៀសវាង ការឲ្យតម្លៃខ្លួនឯង ដោយផ្អែកទៅលើនិទ្ទេសរបស់ពួកគេ តែឲ្យពួកគេទុកចិត្តលើអត្តសញ្ញាណ ដែលពួកគេមានក្នុងព្រះវិញ?

## គឺមានន័យថា យើងត្រូវឲ្យពួកគេខិតខំរៀនសូត្រ

យើងអាចលើកទឹកចិត្តកូនយើង ឲ្យរៀនសូត្រ "ឲ្យអស់ពីចិត្ត"(កូល៉ុស ៣:២៣)។ បានសេចក្ដីថា ពួកគេត្រូវមានភាពឧស្សាហ៍ព្យាយាម។ គឺដូចដែលបទគម្ពីរសុភាសិត ១៣:៤ បានចែងថា :

> *ព្រលឹងនៃមនុស្សខ្ជិលច្រអូសប្រាថ្នាចង់បាន តែមិនបានអ្វីសោះ ឯព្រលឹងនៃមនុស្សព្យាយាម នោះនឹងបានជាបរិបូរវិញ។*

ព្រះគម្ពីរប៊ីបមិនបានបង្គាប់កូនយើង ឲ្យរៀនឲ្យបានពិន្ទុឲ្យខ្ពស់ជាងគេនោះទេ តែពិតជាបានលើកទឹកចិត្តពួកគេ ឲ្យមានភាពឧស្សាហ៍ព្យាយាម និងខិតខំឲ្យអស់ពីលទ្ធភាព។ ការលើកទឹកចិត្តកូនយើងឲ្យមានភាពឧស្សាហ៍ព្យាយាមក្នុងរៀនសូត្រ គឺមិនមែនផ្ទុយនឹងចិត្តរបស់យើង ដែលចង់ដាក់ព្រះ នៅចំណុចកណ្ដាលនៃការប្រណាំងប្រជែងក្នុងការរៀនសូត្រនោះឡើយ។ តាមពិត ព្រះអម្ចាស់សព្វព្រះទ័យ ឲ្យកូនយើងមានការទទួលខុសត្រូវ ចំពោះការសិក្សារបស់ខ្លួន។

អាចនិយាយបានម្យ៉ាងទៀតថា គោលដៅរបស់យើង ក្នុងនាមជាឪពុកម្ដាយ គឺត្រូវលើកទឹកចិត្តកូនយើង ឲ្យខិតខំរៀនសូត្រឲ្យអស់ពីចិត្ត គឺមិនមែនឲ្យខិតខំរៀន ឲ្យមានពិន្ទុខ្ពស់ជាងគេនោះទេ។ បើពួកគេពិតជាបានប្រឹងប្រែងអស់ពីលទ្ធ

ភាពហើយ នោះយើងគួរតែមានមោទនភាពចំពោះពួកគេ ទោះពួកគេមិនបានចំណាត់ថ្នាក់លេខមួយ នៅក្នុងថ្នាក់រៀនក៏ដោយ។

## ការពិចារណា

១. តើខ្ញុំសរសើរកូនខ្ញុំ តែនៅពេលដែលពួកគេរៀនបានពិន្ទុះល្អ នៅសាលារៀនឬ? តើធ្វើដូចម្តេច ឲ្យខ្ញុំអាចរំឭកខ្លួនឯង ឲ្យសរសើរពួកគេ សម្រាប់ការប្រឹងប្រែងអស់ពីសមត្ថភាព?

២. តើខ្ញុំអាចលើកទឹកចិត្តកូនខ្ញុំយ៉ាងដូចម្តេច ដើម្បីឲ្យពួកគេមានការឧស្សាហ៍ព្យាយាមក្នុងការរៀនសូត្រ?

## គឺមានន័យថា យើងត្រូវទុកចិត្តថា ព្រះទ្រង់នឹងរៀបចំអនាគតឲ្យកូនយើង

ការទទួលស្គាល់ថា ព្រះទ្រង់ជាម្ចាស់នៃការប្រណាំប្រជែង ក្នុងការរៀនសូត្រ គឺមានន័យថា យើងអាចទុកចិត្តថា ព្រះអង្គនឹងរៀបចំអនាគតឲ្យកូនយើង។

ព្រះគម្ពីរបានឲ្យយើងងាកបែរទៅរកព្រះ ពេលណាយើងមានការថប់បារម្ភអំពីនិទ្ទេសរបស់កូនយើង និងអំពីមហាវិទ្យាល័យដែលពួកគេនឹងត្រូវទៅរៀន នៅពេលអនាគត ឬបារម្ភថា យើងបានធ្វើគ្រប់គ្រាន់សម្រាប់ពួកគេឬអត់។ ព្រះបន្ទូលព្រះបានធានាចំពោះយើងម្តងហើយម្តងទៀតថា យើង និងកូនរបស់យើង អាចទុកចិត្តព្រះអង្គ គឺដូចមានសេចក្តីចែងថា :

មនុស្សដែលកោតខ្លាចដល់ព្រះយេហូវ៉ា នោះមានទីពឹងមាំមួន ហើយកូនចៅរបស់គេនឹងបានទីពំនាក់ដែរ(សុភាសិត ១៤:២៦)។

*កុំឲ្យខ្វល់ខ្វាយអ្វីឡើយ ចូរទូលដល់ព្រះ ឲ្យជ្រាបពីសេចក្តីសំណូមរបស់អ្នករាល់គ្នាក្នុងគ្រប់ការទាំងអស់ ដោយសេចក្តីអធិស្ឋាន និងពាក្យទូលអង្វរ ទាំងពោលពាក្យអរព្រះគុណផង យ៉ាងនោះ សេចក្តីសុខសាន្តរបស់ព្រះ ដែលហួសលើសពីអស់ទាំងគំនិត និងជួយការពារចិត្ត ហើយនិងគំនិតរបស់អ្នករាល់គ្នា ក្នុងព្រះគ្រីស្ទយេស៊ូវ(ភីលីព ៤:៦-៧)។*

យើងអាចបណ្តេញការថប់បារម្ភ ហើយបន្តមានចិត្តស្ងប់ នៅចំពោះមុខនៃភាពស្រ្តេស ព្រោះព្រះគឺជាទីជ្រកកោនរបស់យើង។ យើងអាចថ្វាយគ្រប់ការទាំងអស់ ដោយការអធិស្ឋាន ដោយទុកចិត្តថា ព្រះអង្គនឹងឃុំគ្រងអនាគតដ៏អស់កល្បរបស់យើង ក្នុងព្រះគ្រីស្ទយេស៊ូវ ហើយលើសពីអាចឃុំគ្រងជីវិតយើង នៅលើផែនដី និងអនាគតរបស់កូនយើង។

យើងងាយនឹងមានចិត្តថប់បារម្ភ ពេលយើងជជែកជាមួយមិត្តភក្តិ ហើយឮពួកគេអួតអំពីកូន ដែលទៅរៀននៅសាលាល្បីៗ ឬបានទៅរៀនគួរបំប៉ន ជាមួយគ្រូដែលល្បីៗ។ ការថប់បារម្ភអាចកើតមាន ក្នុងចិត្តយើង ទោះយើងបានប្រឹងប្រែងអស់ពីលទ្ធភាព ដើម្បីតយុទ្ធនឹងវា។ ទំរាំតែយើងដឹង ទំនុកចិត្តដែលយើងមានចំពោះព្រះ ក៏បានរីងស្ងួតអស់។ ហេតុនេះហើយ ព្រះអង្គបានត្រាស់ហៅយើង ឲ្យ "ផ្លាស់ប្រែ ដោយគំនិតបានកែជាថ្មីឡើង" ជារៀងរាល់ថ្ងៃ គឺមិនមែនតែម្តង។ ពេលណាភាពតក់ស្លុត់ ពេលណាភាពថប់បារម្ភវាយប្រហារមកលើយើង យើងអាចរត់ទៅរកព្រះអង្គ ហើយចាំថា ព្រះអង្គបានត្រាស់ហៅយើងឲ្យកោតខ្លាចព្រះអង្គ ជាជាងខ្លាចលោកិយ។

ការកោតខ្លាចព្រះអម្ចាស់ គឺមានន័យថា យើងទទួលស្គាល់ថា ព្រះអង្គជាម្ចាស់លើជីវិតរបស់យើង និងកូនរបស់យើង។ គឺមានន័យថា យើងទទួលស្គាល់ថា យើងមិនអាចរៀបចំអនាគតឲ្យកូនយើងបានទាំងស្រុងឡើយ។ គឺមានន័យថា យើងលះបង់ចោលការមិនទុកចិត្តរបស់យើង ហើយងាកមកទុកចិត្តព្រះអង្គវិញ។

សរុបមក ព្រះអម្ចាស់ជាអ្នកនាំផ្លូវយើងម្នាក់ៗ។ យើងមិនមានចំណេះដឹងឥតខ្ចោះ អំណាចឥតខ្ចោះ ឬការគ្រប់គ្រងដ៏ឥតខ្ចោះឡើយ។ តែព្រះអង្គមានអ្វីៗគ្រប់យ៉ាងសុទ្ធតែល្អឥតខ្ចោះ។ ព្រះអង្គនឹងមិនបោះបង់កូនព្រះអង្គចោលឡើយ។

ព្រះអង្គជាជំនួយ និងជាខែលដល់អ្នកដែលកោតខ្លាច និងទុកចិត្តព្រះអង្គ។ យើងអាចអធិស្ឋានថ្វាយដំណើរនៃការអប់រំរបស់កូនយើង ដាច់ដល់ព្រះអង្គ ដោយដឹងថា ព្រះអង្គស្រឡាញ់ពួកគេ លើសពីលទ្ធភាពដែលយើងអាចស្រឡាញ់ពួកគេ។

## ការពិចារណា

១. តើខ្ញុំបានទុកចិត្តព្រះច្រើនប៉ុណ្ណា នៅក្នុងដំណើរនៃការអប់រំរបស់កូនខ្ញុំ? តើធ្វើដូចម្ដេចឲ្យខ្ញុំអាចបង្កើនការទុកចិត្តព្រះអង្គ ក្នុងរឿងនេះ?

២. តើធ្វើដូចម្ដេចឲ្យខ្ញុំអាចបន្តកោតខ្លាចព្រះ ខណៈពេលដែលខ្ញុំរៀបចំពេលវេលា និងធនធានរបស់កូនខ្ញុំ?



*ទី៥*

# រស់នៅដោយប្រាជ្ញាមកពីព្រះ

ខាងក្រោមនេះ **គឺជាសេចក្ដីសង្ខេប** នៃអ្វីដែលយើងបានស្វែងយល់រហូតមកដល់ចំណុចនេះ :

១. កូនជាអំណោយមកពីព្រះ

២. ក្មេងម្នាក់ៗសុទ្ធតែត្រូវបានព្រះទ្រង់បង្កើតមក ឲ្យមានលក្ខណៈពិសេសរៀងៗខ្លួន

៣. ដូចនេះ យើងគួរតែជៀសវាងការប្រៀបធៀបកូនយើងជាមួយអ្នកដទៃ។

៤. កូនជាមនុស្ស មិនមែនជាផលិតផលទេ

៥. យើងមានឯកសិទ្ធិជាអ្នកបម្រើដ៏ស្មោះត្រង់ ដែលព្រះបានប្រទានកូនឲ្យដឹកនាំ និងបង្រៀន

៦. អាទិភាពទីមួយរបស់យើង គឺត្រូវបង្រៀនពួកគេឲ្យស្គាល់ និងស្រឡាញ់ព្រះ

៧. យើងត្រូវតែញែកពេល និងធនធាន ដើម្បីយកព្រះជាទីមួយ ជាសំខាន់ជាងកាលវិភាគនៃការរៀនសូត្ររបស់កូនយើង

៨. យើងត្រូវប្រាកដថា កូនយើងមានពេលវេលា សម្រាប់នឹកចាំអំពីព្រះ

៩. យើងមិនត្រូវរុញច្រានកូនយើងឲ្យមានកំហឹង ដោយបដិសេធពួកគេ និង អនុញ្ញាតឲ្យភាពល្ងីងល្ងើជួរចត់លូតលាស់ ក្នុងពួកគេឡើយ

១០. ការបង្កើតរូបព្រះ ក្នុងចិត្តយើង អាចជាមូលហេតុចម្បង ដែលនាំឲ្យយើង មានអារម្មណ៍ស្រ្តេស អំពីការប្រណាំប្រជែង ក្នុងការរៀនសូត្ររបស់កូន

១១. ព្រះបានត្រាស់ហៅយើង ឲ្យលះបង់ចោលរូបព្រះ ដែលយើងមាន ទោះវាជា រូបព្រះនៃការរៀនសូត្រ ឬរូបព្រះនៃជោគជ័យក្ដី

១២. ការអប់រំ គឺជាឱកាសដ៏អស្ចារ្យ សម្រាប់រៀនអំពីស្នាព្រះហស្តរបស់ព្រះ និង អំពីព្រះអង្គ។

១៣. ព្រះអង្គជាព្រះអម្ចាស់ នៃការប្រណាំប្រជែង ក្នុងការរៀនសូត្ររបស់កូនយើង

១៤. កូនៗរបស់យើងត្រូវតែរៀនសូត្រ ដើម្បីព្រះ គឺមិនមែនដើម្បីយើង ឬដើម្បី ខ្លួនឯងនោះឡើយ

១៥. ការរៀនសូត្រ ដើម្បីព្រះ គឺមានន័យថា យើងថ្វាយសិរីល្អដល់ព្រះ យើងងាក ទៅរកព្រះអង្គ ដើម្បីទទួលកម្លាំង ហើយយើងនឹកចាំថា យើងមិនត្រូវឲ្យតម្លៃកូន យើង ដោយផ្អែកទៅលើនិទ្ទេសរបស់ពួកគេ តែផ្អែកទៅលើព្រះ

១៦. ការរៀនសូត្រ ដើម្បីព្រះ ក៏មានន័យថា កូនយើងត្រូវឧស្សាហ៍ព្យាយាម ក្នុង ការរៀនសូត្រ

១៧. គោលដៅរបស់យើង គឺដើម្បីឲ្យកូនយើងខិតខំអស់ពីចិត្ត មិនមែនដើម្បីឲ្យ ពូកែជាងគេនោះទេ

១៨. យើងគួរតែមានមោទនៈភាពចំពោះពួកគេ ពេលណាពួកគេខិតខំអស់ពីចិត្ត

១៩. យើងអាចទុកចិត្តថា ព្រះនឹងឃុំគ្រងអនាគតរបស់កូនយើង

២០. ចូរកោតខ្លាចព្រះអម្ចាស់ ហើយទុកចិត្តព្រះអង្គជារៀងរាល់ថ្ងៃ ដ្បិតព្រះអង្គ ជាជំនួយ និងខែលរបស់យើង ក្នុងការប្រណាំងប្រជែង ក្នុងការរៀនសូត្ររបស់កូន យើង

គ្មានរូបមន្តណាមួយ ដែលអាចធានាថា កូនរបស់អ្នកនឹងឆ្លងកាត់ការប្រណាំងប្រជែង ក្នុងការរៀនសូត្របានជោគជ័យនោះឡើយ។ គ្រួសារនីមួយៗស្ថិតក្នុងកាលៈទេសៈខុសៗគ្នា ហើយក្មេងម្នាក់ៗក៏មានលក្ខណៈខុសពីគ្នាផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ព្រះគម្ពីរបានផ្តល់ឲ្យយើង នូវប្រាជ្ញាដ៏អស់កល្ប និងមិនចេះប្រែប្រួល ដែលយើងអាចទុកដាក់ ក្នុងចិត្តយើង។

ជាការពិតណាស់ គេអាចឆ្លងកាត់ការប្រណាំប្រជែងក្នុងការរៀនសូត្រ ដោយគ្មានព្រះ។ កូនរបស់យើងថែមទាំងអាចឈ្នះការប្រណាំងប្រជែងនេះ ដោយលទ្ធផលដ៏ឥតខ្ចោះ។ ប៉ុន្តែ ពួកគេនឹងទទួលបានទ្រព្យសម្បត្តិ ដែលមានតម្លៃបំផុត ក្នុងជីវិតឬទេ?

មានពេលមួយ អ្នកស្រីស្តេហ្វិននី(Stefanie) បានទទួលដំណឹងថា កូនស្រីគាត់ ឈ្មោះ ខេយឡា(Kayla) បានប្រឡងជាប់អាហាររូបករណ៍១រយភាគរយទៅរៀននៅសាលាស្តេនហ្វិត នៅអាមេរិក។ វាជាពេលដ៏រីករាយ ដែលគាត់មិនអាចបំភ្លេចបាន។ អ្នកស្រីស្តេហ្វានីលះបង់ពេលវេលា និងធនធាន អស់ពីលទ្ធភាព ដើម្បីការរៀនសូត្ររបស់ខេយឡា។ ទោះជាយ៉ាងណាក៏ដោយ គាត់មានការឈឺចិត្តយ៉ាងខ្លាំង ពេលដែលខេយឡាសារភាពថា "ម៉ាក់ ខ្ញុំឈប់ជឿព្រះហើយ"។

ជាការពិតណាស់ តើវាមានប្រយោជន៍អ្វី បើកូនរបស់យើងយកបានពិភពលោកទាំងមូល តែបាត់វិញ្ញាណទៅ(ម៉ាកុ ៨:៣៦)? តើយើងគួរតែងប់ងល់នឹងការរៀនសូត្ររបស់កូនយើងខ្លាំងពេក បានជាយើងភ្លេចនាំកូនយើងឲ្យស្រឡាញ់ព្រះជាអាទិភាពទីមួយឬ? ក្នុងនាមជាឪពុកម្តាយ យើងមានឯកសិទ្ធិ ធ្វើជាអ្នកបម្រើដ៏ស្មោះត្រង់ និងមានការទទួលខុសត្រូវដ៏បរិសុទ្ធ ក្នុងការបង្រៀនកូនរបស់យើង។ ដូចនេះ ចូរយើងថយមួយជំហាន ហើយជញ្ជឹងគិតថា "តើមានការអ្វីមួយ ដែលខ្ញុំពិតជាមិនចង់ឲ្យពួកគេបោះបង់ចោល? តើមានការអ្វីមួយ ដែលពួកគេពិតជាត្រូវការ ក្នុងជីវិត?" អ្វីដែលពួកគេមិនត្រូវបោះបង់ចោល និងត្រូវការជាទីបំផុត គឺការទំនាក់ទំនងដ៏សកម្មជាមួយព្រះអម្ចាស់ យេស៊ូវគ្រីស្ទ ដែលមានការលូតលាស់ជានិច្ច។

ជាការពិតណាស់ ខណៈពេលដែលយើងកំពុងតែមានស្រ្តេស ដោយសារការប្រណាំងប្រជែង ក្នុងការរៀនសូត្ររបស់កូន វិញ្ញាណរបស់យើងប្រហែលជាមិននឹងនរ ហើយក៏ភ្លេចផ្តោតចិត្តទៅលើព្រះ។ ដើម្បីឲ្យយើងអាចបន្តកោតខ្លាច និងទុកចិត្តព្រះ សូមអនុវត្តតាមគោលការណ៍ដូចតទៅ :

## ចូរពិនិត្យមើលចិត្តខ្លួនឯង ឲ្យបានទៀងទាត់

១. ចូរជញ្ជឹងគិត : ចូរចំណាយពេលជាមួយព្រះ ឲ្យបានទៀងទាត់ ហើយញែកពេលសម្រាប់ព្រះអង្គ និងព្រះបន្ទូលព្រះអង្គ។ សូមជញ្ជឹងគិតអំពីសំណួរ ដែលមានក្នុងសៀវភៅនេះ ហើយកត់ត្រាអ្វីដែលមានក្នុងគំនិតអ្នក។ ចូរត្រឡប់មករកសំណួរទាំងនេះឡើងវិញ ឲ្យបានទៀងទាត់។

២. ចូរអធិស្ឋាន ឲ្យខ្លួនឯង : ចូរទូលសូមការអត់ទោសបាបពីព្រះ បើសិនជាពេលនេះ អ្នកមិនបានដើរតាមប្រាជ្ញាក្នុងព្រះគម្ពីរ ក្នុងការនាំកូនអ្នកឆ្លងកាត់ការប្រណាំងប្រជែង ក្នុងការអប់រំ។ ចូរទូលសូមព្រះអម្ចាស់បង្ហាញអ្នក នូវអ្វីដែលអ្នកចាំបាច់ត្រូវផ្លាស់ប្តូរ ដូចជាការចំណាយពេលវេលា និងធនធាន ដោយប្រាជ្ញា ការផ្តោតទៅលើការសន្ទនាក្នុងគ្រួសារ អំពីព្រះ ឬការបង្ហាញចេញនូវអាកប្បកិរិយាដ៏ត្រឹមត្រូវ ដល់កូនរបស់អ្នក។ ចូរទូលសូមព្រះអម្ចាស់បង្រៀនអ្នក ឲ្យស្តាប់បង្គាប់ និងទុកចិត្តព្រះអង្គ។

៣. ចូរអធិស្ឋានឲ្យកូនរបស់អ្នក : ចូរទូលសូមព្រះអម្ចាស់ជួយកូនអ្នក ឲ្យរកឃើញស្នាព្រះហស្តព្រះអង្គ តាមរយៈការអប់រំ និងរៀនសូត្រថ្វាយព្រះអង្គ ដោយឧស្សាហ៍ព្យាយាម។

## ចូរមានចិត្តដែលចង់ :

១. រត់គេចពីការល្បួង : ចូររត់គេចពីស្ថានភាព ដែលអាចល្បួងអ្នក ឲ្យជាប់ខ្លួននៅក្នុងការប្រកួតប្រជែង ក្នុងការអប់រំរបស់កូណ។ ឧទាហរណ៍ : ចូរជៀសវាងស្ថានភាព ឬការសន្ទនា ដែលអាចធ្វើឲ្យអ្នកមានចិត្តថប់បារម្ភ ដែលមិនចាំបាច់។

២. ផ្លាស់ប្តូរ : ចូរទូលសូមព្រះឲ្យជួយអ្នក ឲ្យផ្លាស់ប្តូរទស្សនៈ និងអាទិភាពរបស់

អ្នក ហើយអនុញ្ញាតឲ្យព្រះអង្គកែប្រែអ្នកជាថ្មី តាមរយៈព្រះវិញ្ញាណ និងព្រះបន្ទូលព្រះអង្គ។ ចូរទូលសូមព្រះអង្គ ឲ្យជួយកែប្រែពាក្យសម្ដីរបស់អ្នក ពេលដែលអ្នកនិយាយទៅកាន់កូនអ្នក និងកែប្រែសកម្មភាព និងការសម្រេចចិត្តរបស់អ្នក ទាក់ទងនឹងការធ្វើដំណើរនៃការអប់រំរបស់កូនអ្នក ពីមួយថ្ងៃទៅមួយថ្ងៃ(រ៉ូម ១២:២)។

## ចូរមានការទទួលខុសត្រូវ ចំពោះ :

១. ប្ដីប្រពន្ធរបស់អ្នក : ចូររួមកម្លាំងជាមួយប្ដីប្រពន្ធរបស់អ្នក ដើម្បីធ្វើឲ្យប្រាជ្ញាក្នុងព្រះគម្ពីរ ក្លាយជាគ្រឹះ នៃជីវិតគ្រួសាររបស់អ្នក។ អ្នកអាចប្រើសំណួរដែលមានក្នុងផ្នែក ការពិចារណា ក្នុងទំព័រមុនៗ។

២. សហគមន៍របស់អ្នក : ចូរស្វែងរកឪពុកម្ដាយដទៃទៀតដែលជាគ្រីស្ទបរិស័ទ ដែលអាចផ្ដល់ជំនួយខាងវិញ្ញាណ ដល់អ្នក ហើយជួយឲ្យអ្នកមានការទទួលខុសត្រូវ។ ចូរអធិស្ឋានជាមួយពួកគេ ហើយចែករំលែកបទពិសោធន៍របស់អ្នក ឲ្យបានទៀងទៀត។

ពេលណាយើងថ្វាយការភ័យខ្លាច និងការរំពឹងចង់បានរបស់យើង ដាច់ដល់ព្រះ យើងនឹងមានការថប់បារម្ភកាន់តែតិច។ យើងនឹងអាចទុកចិត្តថា ទោះយើងទទួលលទ្ធផលយ៉ាងណាក៏ដោយ ព្រះយុំគ្រងអនាគតរបស់កូនយើងជានិច្ច។

ក្មេងខ្លះទទួលលទ្ធផលល្អក្នុងការរៀនសូត្រ។ ក្មេងខ្លះរៀនពូកែ ក្នុងមុខវិជ្ជាខ្លះ តែមិនពូកែ នៅក្នុងមុខវិជ្ជាផ្សេងទៀត។ ព្រះបង្កើតកូនយើងដោយសេចក្ដីស្រឡាញ់ ឲ្យពួកគេមានលក្ខណៈពិសេសរៀងៗខ្លួន និងមានវិញ្ញាណដ៏អស់កល្ប។ គោលដៅរបស់យើង គឺត្រូវនាំពួកគេឲ្យស្គាល់ព្រះអង្គ ហើយស្រឡាញ់ព្រះអង្គអស់ពីចិត្ត គំនិត និងវិញ្ញាណ។ យើងអាចបង្រៀនពួកគេ ឲ្យចាត់ទុកការអប់រំជាការរៀនសូត្រអំពីស្នាព្រះហស្តរបស់ព្រះ ឲ្យរៀនសូត្រដើម្បីព្រះអង្គ ឲ្យឧស្សាហ៍ព្យាយាមក្នុងការរៀនសូត្រ ហើយខិតខំអស់ពីចិត្ត។

ខណៈពេលដែលយើងបន្តប្រឹងប្រែងអស់ពីលទ្ធភាព ដើម្បីកូនយើង ចូរយើងកុំភ្លេចអាទិភាពទីមួយរបស់យើង ដែលត្រូវបង្រៀនពួកគេឲ្យស្រឡាញ់ព្រះ និងយកព្រះអង្គជាទីមួយ។ យើងចាំបាច់ត្រូវចាំថា គោលដៅធំបំផុតរបស់យើង គឺត្រូវ

ជួយពួកគេឲ្យមានទំនាក់ទំនងនៃសេចក្តីស្រឡាញ់ជាមួយព្រះគ្រីស្ទ ដោយផ្ទាល់ខ្លួន។

ខណៈពេលដែលយើងធ្វើដំណើរជាមួយកូនយើង ក្នុងការអប់រំរបស់ពួកគេ យើងអាចបង្ហាញពួកគេថា យើងក៏ត្រូវការប្រាជ្ញាមកពីព្រះ ដើម្បីឆ្លងកាត់ការប្រណាំងប្រជែង ក្នុងការអប់រំផងដែរ។ ការរៀនប្រឈមមុខដាក់ការប្រណាំងប្រជែងនេះ តាមព្រះគម្ពីរ អាចនាំឲ្យយើងមានការលូតលាស់ខាងវិញ្ញាណ ទាំងសម្រាប់ខ្លួនឯង និងកូនយើង។ សូមឲ្យកូនយើងមើលឃើញយើងពឹងផ្អែកលើព្រះ ដោយសូមឲ្យពួកគេថ្វាយជីវិតដល់ព្រះអង្គ បន្ទាប់ពីបានមើលឃើញទីបន្ទាល់ល្អរបស់យើង។

ឱព្រះអម្ចាស់ ទូលបង្គំទទួលស្គាល់ថា ព្រះអង្គជាអ្នកបង្កើតកូនរបស់ទូលបង្គំមក។ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានបង្កើតពួកគេមក ឲ្យមានលក្ខណៈពិសេស និងអស្ចារ្យរៀងៗខ្លួន ហើយព្រះអង្គមានផែនការសម្រាប់ពួកគេម្នាក់ៗ។សូមបង្ហាញទូលបង្គំ អំពីរបៀបដែលទូលបង្គំអាចបង្រៀនកូនទូលបង្គំឲ្យស្រឡាញ់ព្រះអង្គ អស់ពីចិត្ត វិញ្ញាណ និងកម្លាំង។ សូមជួយទូលបង្គំឲ្យញែកពេលវេលា និងធនធាន ដោយយកព្រះអង្គជាទីមួយ។ សូមជួយទូលបង្គំ ឲ្យទុកពេលវេលាឲ្យកូនទូលបង្គំសម្រាក ដើម្បីឲ្យពួកគេមានពេលនឹកចាំ អំពីព្រះអង្គ។ សូមដកការថ្វាយបង្គំរូបព្រះចេញពីចិត្តទូលបង្គំ ហើយជួយទូលបង្គំ ឲ្យមើលឃើញការអប់រំ ជាឱកាស សម្រាប់ឲ្យកូនទូលបង្គំស្ងប់ស្ងែង ចំពោះស្នាព្រះហស្តព្រះអង្គ ហើយរកឃើញស្នាព្រះហស្តដ៏អស្ចារ្យរបស់ព្រះអង្គ ដើម្បីឲ្យពួកគេខិតខំរៀនសូត្រ ដើម្បីថ្វាយសិរីល្អដល់ព្រះអង្គ។ ទូលបង្គំសូមអធិស្ឋាន ឲ្យពួកគេប្រឹងប្រែងអស់ពីចិត្ត ហើយអធិស្ឋាន សូមឲ្យទូលបង្គំបន្តទុកចិត្តព្រះអង្គ។ សូមធ្វើជាជំនួយ និងជាខែលរបស់ទូលបង្គំ។ សូមប្រើអ្វីៗទាំងអស់ សូម្បីតែកំហុសរបស់ទូលបង្គំ ដើម្បីនាំកូនទូលបង្គំទៅរកព្រះអង្គ។ នៅទីបញ្ចប់ ទូលបង្គំសូមអធិស្ឋាន ឲ្យពួកគេ មានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះអង្គ ដែលជាព្រះដ៏រស់លើអ្វីៗទាំងអស់។

# BIBLICAL WISDOM *for* PARENTS

Visit **www.biblical-parenting.org** for




- Biblical wisdom on parenting, based on God's Word
- Practical tips & advice from experts and parents
- Inspiring stories from parents who've walked the same journey
- Daily prayer to help you pray for your family
- Resources for the whole family




Our Daily Bread. | Love God. Love Others.
BIBLICAL WISDOM for PARENTS
Article
Investing in the Family
The right priority, place, and person for teaching spiritual values to kids.
Continue Reading
I want to teach my child to pray
Articles
Continue Reading
Help!
My teenager doesn't want to go to church.
Articles
Continue Reading
I want my child to read the Bible
Articles
Continue Reading

# ធនធានរបស់យើងខ្ញុំ

នំម៉ាណាប្រចាំថ្ងៃ មានសម្ភារៈជាច្រើន ដែលផ្អែកទៅលើព្រះគម្ពីរ សម្រាប់ការបោះជំហាននីមួយៗ ក្នុងការធ្វើដំណើរខាងវិញ្ញាណរបស់អ្នក ជាជំនួយដល់អ្នក ខណៈពេលដែលអ្នកស្វែងរកក្តីអំណរ ក្នុងការដើរជាមួយព្រះយេស៊ូវគ្រីស្ទ។ យើងខ្ញុំបានរៀបចំធនធាន សម្រាប់អ្នកស្វែងរកសេចក្តីពិត ក៏ដូចជាអ្នកជឿ ដែលកំពុងស្ថិតក្នុងដំណាក់កាលនីមួយៗ នៃការធ្វើដំណើរខាងវិញ្ញាណ។ ទោះអ្នកកំពុងតែស្វែងយល់អំពីជំនឿគ្រីស្ទបរិស័ទ កំពុងតែចាប់ផ្តើមដោយជំនឿ កំពុងតែពេញវ័យក្នុងការដើរជាមួយព្រះ ឬកំពុងឈោងចាប់អ្នកដទៃ ដោយដំណឹងល្អក្តី យើងខ្ញុំមានធនធានដែលអ្នកអាចប្រើ និងចែករំលែក ដែលផ្តោតទៅលើប្រធានបទដូចជា :

- **ការស្វែងរកព្រះគ្រីស្ទ** : គឺធនធានដែលអញ្ជើញអ្នក ឲ្យស្វែងយល់អំពីជំនឿគ្រីស្ទបរិស័ទ
- **ការស្វែងយល់អំពីព្រះគ្រីស្ទ** : គឺធនធានដែលអញ្ជើញអ្នក ឲ្យមានការយល់ដឹងកាន់តែស៊ីជម្រៅ អំពីដំណឹងល្អ
- **ការលូតលាស់ក្នុងព្រះគ្រីស្ទ** : គឺធនធានដែលជួយអ្នក ឲ្យចាប់ផ្តើមការធ្វើដំណើរនៃជំនឿរបស់អ្នក
- **ការចូលទៅជិតព្រះគ្រីស្ទ** : គឺធនធានដែលជួយអ្នក ឲ្យប្រើ និងបង្ហាញជំនឿរបស់អ្នក
- **ការផ្តោតទៅលើព្រះគ្រីស្ទ** : គឺធនធានដែលជួយអ្នក ក្នុងការបម្រើ និងផ្សាយដំណឹងល្អ

ដើម្បីស្វែងយល់បន្ថែម សូមចូលក្នុងវេបសាយ : www.khmer-odb.org

## នំម៉ាណាប្រចាំថ្ងៃ




សូមចំណាយពេលប្រចាំថ្ងៃជាមួយព្រះបន្ទូលព្រះ ដោយប្រើសៀវភៅនំម៉ាណាប្រចាំថ្ងៃ ដ៏ពេញនិយម សម្រាប់ប្រកបជាមួយព្រះប្រចាំថ្ងៃ ដែលលើកទឹកចិត្តអ្នកអាន ឲ្យជញ្ជឹងគិតព្រះបន្ទូលព្រះ។ ទន្ទឹមនឹងនោះ អ្នកក៏អាចអានខគម្ពីរខ្លីៗ និងអត្ថបទដែលប្រើទីបន្ទាល់នៃជីវិតពិត ក្នុងការបកស្រាយគោលការនៃព្រះគម្ពីរ និងលើកទឹកចិត្តអ្នកអាន ឲ្យប្រើប្រាស់ការបង្រៀននោះ ក្នុងជីវិតផ្ទាល់ខ្លួនផងដែរ។ សៀវភៅនំម៉ាណាប្រចាំថ្ងៃ ត្រូវបានចែកផ្សាយ ជាង៥០ភាសា ទូទាំងពិភពលោក និងត្រូវបានមនុស្សរាប់លាននាក់អានជារៀងរាល់ថ្ងៃ។ ហើយក៏មានជាភាសាខ្មែរ ដែលយើងខ្ញុំបានបោះពុម្ពផ្សាយ ផ្តល់ជូនតាមអនឡាញ នៅក្នុងapp និងអ៊ីមែល។

## ក្រុមសៀវភៅការរុករកឃើញ

លោកអ្នកអាចមានការយល់ដឹង និងស្រឡាញ់ព្រះបន្ទូលព្រះកាន់តែស៊ីជម្រៅ ដោយប្រើសៀវភៅការរុករកឃើញរបស់យើងខ្ញុំ។ សូមស្វែងយល់បន្ថែមអំពីព្រះ ព្រះគម្ពីរ ជំនឿគ្រីស្ទបរិស័ទ និងការអនុវត្តន៍ និងប្រធានបទជាច្រើនទៀត ក្នុងអត្ថបទដ៏មានន័យ ដែលផ្តល់ឲ្យនូវការបង្រៀនព្រះគម្ពីរ និងយោបលដ៏មានប្រសិទ្ធភាព អំពីការរស់នៅជាគ្រីស្ទបរិស័ទ។ អ្នកក៏អាចស្វែងរកសៀវភៅទាំងនេះបានក្នុងវេបសាយ : www.khmer-odb.org/ds/

